ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ជំនាញទីផ្សារខ្ញុំ

## (ឯកសារសម្រាប់គ្រូ)



**បំណិនជីវិតសម្រាប់ថ្នាក់ទី៦ និងទី៧**
**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា**

USAID ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**គណៈកម្មការអភិវឌ្ឍសៀវភៅ**

**"ជំនាញទីផ្សារខ្ញុំ"**

**គណៈកម្មការនិពន្ធនិងរៀបរៀង**

១. លោកស្រី អេលិន ជោច (Eileen St. George)

២. លោក ចាន់ ណារិន

៣. លោក សៅ ប៊ុនធឿន

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន

២. លោកស្រី មុំ មេត

៣. លោក ប៉ុល សុរិទ្ធ

**គណៈកម្មការពិនិត្យ**

១. លោក ព្រំ វិបុល

២. លោក មាស ជុតិមា

៣. លោក ហួត នរៈ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍអន្តរជាតិ (USAID)

រៀបចំដោយ អង្គការអប់រំពិភពលោក

សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា

ទំព័រ

អារម្ភកថា........................................................................................ ០១
ការណែនាំអនុវត្ត.................................................................................. ០២
មេរៀនទី១ : បញ្ជីគណនេយ្យ ចំណូល និង ចំណាយ............................................ ០៣
មេរៀនទី២ : តារាងលំហូរសាច់ប្រាក់ ............................................................. ០៩
មេរៀនទី៣ : ការស្វែងយល់ពីការអនុវត្តបញ្ជីគណនេយ្យ........................................... ១៩
មេរៀនទី៤ : ការកំណត់តម្លៃទំនិញ..................................,,,......................... ២៣
មេរៀនទី៥ : ការស្វែងយល់ពីការកំណត់តម្លៃទំនិញ................................................ ២៨
មេរៀនទី៦ : ការពិនិត្យប្រាក់អាប់............................................................... ៣១
សង្ខេបខ្លឹមសារនៃឯកសារណែនាំ ................................................................ ៣៦

**អារម្ភកថា**

ឯកសារស្តីអំពី " ជំនាញទីផ្សារខ្ញុំ " មានបំណងជួយអ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹង បំណិន និង បទពិសោធន៍ក្នុងផ្នែកបំណិនជីវិតងាយៗ ទាក់ទងនឹងការគ្រប់គ្រងប្រាក់។ ការសិក្សាច្រើនពីភាពត្រឹមត្រូវតាមច្បាប់ និង ពីការទទួលខុសត្រូវក្នុងការតាមដានប្រតិបត្តិការងារហិរញ្ញវត្ថុដែលកើតឡើងនៅក្នុងទីផ្សារ និង កន្លែងធ្វើការ ដែលនឹងជួយយុវជន-យុវនារីឱ្យចៀសផុតពីបញ្ហាប្រឈមដែលបណ្តាលមកពីកង្វះការយល់ដឹងក្នុងមុខជំនួញ ឬការលក់ដូរ។

យើងសង្ឃឹមថាយុវជនបច្ចុប្បន្នអាចមានការគិតដោយមានផែនការ និង មានគោលបំណងក្នុងការគ្រប់គ្រងប្រាក់ របស់គេតាមរយៈការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និង ជំនាញក្នុងការកត់ត្រាបញ្ជីគណនេយ្យ ការគ្រោងថវិកា ការកំណត់ថ្លៃ ការឱ្យតម្លៃលើការធ្វើផែនការ ការរៀបចំថវិកា និង សមត្ថភាពលើការគណនាប្រតិបត្តិការសាច់ប្រាក់។

## ការណែនាំអនុវត្ត

### ☑ ការរៀបចំរបស់គ្រូមុនការបង្រៀន

គ្រូត្រូវអានកិច្ចតែងការបង្រៀនប្រចាំថ្ងៃមុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈបង្រៀនត្រូវបានផលិត ឬត្រូវបានរៀបចំរួច អាចប្រើប្រាស់ក្នុងសកម្មភាពរៀន និងបង្រៀនដោយស្ទាត់ជំនាញ និងមានប្រសិទ្ធភាព។

### 🕒 រយៈពេលបង្រៀន

មេរៀននីមួយៗត្រូវបង្រៀនក្នុងរយៈពេល២ម៉ោងសិក្សា

### 📖 សម្ភារៈ

សម្ភារៈដែលត្រូវការមានសរសេរនៅក្នុងមេរៀននីមួយៗ។ គ្រូគួរពិនិត្យមើលមេរៀនមុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈដែលចាំបាច់ទាំងអស់បានទទួលឬបានផលិតជាស្រេច។ សៀវភៅសិស្សមានសារៈសំខាន់សម្រាប់សិស្ស ប៉ុន្តែវាក៏ចាំបាច់សម្រាប់ការបង្រៀនមុខវិជ្ជាបំណិនជីវិតស្តីពីជំនាញទីផ្សាររបស់ខ្ញុំនេះដែរ។ ខ្លឹមសារនៅក្នុងសៀវភៅសិស្សមានសំណួរពិភាក្សា និងសកម្មភាពដែលទាក់ទងនឹងការបង្រៀន។

### ☼ លទ្ធផលសិក្សារំពឹងទុក

នៅក្នុងមេរៀននីមួយៗ មានសរសេរអំពីលទ្ធផលសិក្សារំពឹងទុក។ លទ្ធផលសិក្សាដែលបង្ហាញនៅក្នុងឯកសារនេះ គឺដើម្បីជួយគ្រូឱ្យយល់អំពីវត្ថុបំណងសំខាន់ៗសម្រាប់មេរៀននីមួយៗ និង ឱ្យគ្រូគិតពីសកម្មភាពដែលត្រូវដឹកនាំក្នុងពេលបង្រៀននិងរៀន។ ប្រសិនបើគ្រូចងចាំលទ្ធផលសិក្សាបានច្បាស់លាស់ គ្រូនឹងអាចវាយតម្លៃបានថាតើមេរៀនដែលខ្លួនបង្រៀនអាចឆ្លើយតបនឹងវត្ថុបំណងបានហើយឬនៅ។

## មេរៀនទី ១ : បញ្ជីគណនេយ្យ ចំណូល និង ចំណាយ

🕑 **រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- មើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរពីការសម្តែងតួក្នុងសកម្មភាពទី ៣ នៅលើក្រដាសដាច់ដោយឡែកពីគ្នា
- សរសេរកម្រងសំនួរ និងខ្លឹមសារមេរៀន

🕮 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចបានរៀបរាប់ខាងលើ
- ក្តារខៀន និង ដីស ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- ពន្យល់បានពីសារៈសំខាន់នៃបញ្ជីគណនេយ្យមុខជំនួញ
- លើកឧទាហរណ៍ពីការអនុវត្តល្អ និង មិនល្អនៅលើការចំណាយក្នុងមុខជំនួញ និង បញ្ជាក់ពីមូលហេតុ
- លើកឧទាហរណ៍ពីប្រាក់ចំណូល និង ចំណាយក្នុងកិច្ចការជំនួញបានយ៉ាងតិច ៥ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១: សេចក្តីផ្តើម | 🕑: ១០ នាទី |
|---|---|

១- គ្រូបង្ហាញប្រធានបទសម្រាប់ថ្ងៃនេះ

- សៀវភៅនេះមានឈ្មោះថា "**ជំនាញទីផ្សារខ្ញុំ** "។
- ប្រធានបទនៅថ្ងៃនេះគឺនិយាយអំពី **បញ្ជីគណនេយ្យ : ប្រាក់ចំណូល និង ចំណាយ**។

២- គ្រូធ្វើការបង្ហាញយ៉ាងសង្ខេប ដោយផ្អែកលើព័ត៌មានដូចតទៅ:

នៅប្រទេសកម្ពុជា មនុស្ស ក្រុមគ្រួសារ និង សហគមន៍ជាច្រើនបានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូល ដើម្បីរកចំណូលចូលផ្ទះ ។ ការយល់ដឹងពីគោលការណ៍គ្រឹះ នៃការគ្រប់គ្រងប្រាក់មានសារៈសំខាន់ ដើម្បីរក្សាឱ្យបាននូវប្រាក់ចំណូលចូលផ្ទះឱ្យមាននិរន្តរភាព ។

៣- គ្រូអានគោលបំណងនៃការសិក្សាសម្រាប់មេរៀនថ្ងៃនេះ ។

| សកម្មភាពទី២ : ការពិភាក្សាអំពីជំនួញ នៅក្នុងសហគមន៍របស់អ្នក | ⏲: ១០ នាទី |
|---|---|

១. ការពិភាក្សា : គ្រូនាំសិស្សពិភាក្សាផ្អែកលើសំណួរខាងក្រោម :

- ដូចម្ដេចហៅថាជំនួញ?
  - [ចម្លើយរំពឹងទុក : ជំនួញគឺជាសកម្មភាពនានាដែលអ្នកធ្វើដើម្បីរកប្រាក់ចំណូល តាមគោលការណ៍ជាក់លាក់មួយ ។ ជំនួញអាចជាការផលិត និង ការលក់ទំនិញ ការទិញ និង លក់ទំនិញ និងជាការផ្ដល់សេវាកម្មផងដែរ ។]
- តើនៅក្នុងសហគមន៍របស់យើងមានប្រភេទជំនួញឈ្មោះអ្វីខ្លះ?
  - [ចម្លើយរំពឹងទុក : ចម្លើយជាក់ស្ដែងរបស់សិស្ស ។]
- តើអ្នកធ្វើដូចម្ដេចទើបដឹងថាការធ្វើជំនួញទទួលបានប្រាក់ចំណូល និង ប្រាក់ចំណាយប៉ុន្មាន?
  - [ចម្លើយរំពឹងទុក : អ្នកធ្វើជំនួញត្រូវតែគិតពីប្រាក់ចំណូល និង ប្រាក់ចំណាយដែលកើតមានក្នុងការធ្វើជំនួញ មានន័យថា ពួកគេត្រូវមានសៀវភៅកត់ត្រាពីចំនួនប្រាក់ដែលចេញ និង ចូល ។]
- តើបញ្ជីគណនេយ្យមានន័យដូចម្ដេច?
  - [ចម្លើយរំពឹងទុក : បញ្ជីគណនេយ្យមានន័យថាជាការកត់ត្រារាល់ប្រាក់ចំណូល និងប្រាក់ចំណាយនៅក្នុងការធ្វើជំនួញ រួមបញ្ចូលទាំងការលក់ជឿផងដែរ ។]

២. គ្រូពន្យល់បន្ថែម :

ជាទូទៅនៅក្នុងសហគមន៍របស់យើង ប្រជាពលរដ្ឋជាច្រើនមិនទម្លាប់កត់ត្រាពីចំនួនប្រាក់ចំណូល និងប្រាក់ចំណាយនៅក្នុងមុខជំនួញទេ ព្រោះពួកគេមិនដែលបានទទួលការបង្រៀនពីរបៀបកត់ត្រាប្រាក់ចំណូល និងចំណាយនោះឡើយ ។ ហេតុដូចនេះ ប្រជាពលរដ្ឋពិតជាមិនបានដឹងពីចំនួនប្រាក់ដែលគេ រកបាន ហើយក៏គេមិនអាចចាំឈ្មោះភ្ញៀវដែលបានទិញជឿ ។ ម្យ៉ាងទៀតគេក៏មិនអាចដឹងពិតប្រាកដពីចំនួនទំនិញក្នុងស្តុករបស់គេដែលត្រូវបានទិញជឿនោះដែរ ។ ក្រុមមនុស្សដែលគ្មានចំណេះដឹងពីការរៀបចំបញ្ជីគណនេយ្យក្នុងការចំណាយលើកិច្ចការជំនួញ វាអាចធ្វើឱ្យបាត់បង់ទំនុកចិត្ត និងមានការចោទប្រកាន់កើតឡើងទៀតផង ។

៣. គ្រូសួរ "តើការរៀបចំបញ្ជីគណនេយ្យមានសារៈសំខាន់ដូចម្ដេចខ្លះ?"

[ចម្លើយរំពឹងទុក

- យើងអាចដឹងពីចំនួនប្រាក់ដែលទទួលបាន ចំនួនប្រាក់ដែលបានចំណាយ និង ប្រភេទចំណាយប្រាក់ទាំងនោះ ។
- យើងអាចគណនាដឹងពីប្រាក់ចំណេញ ឬ ប្រាក់ខាតបង់ ។
- យើងអាចធ្វើការសំរេចចិត្តកាន់តែល្អប្រសើរទៅលើអ្វីដែលត្រូវទិញ និង លក់ ។
- យើងអាចកត់ត្រាពីការទិញជឿ ហើយអាចកាត់បន្ថយបានការលួចបន្លំពីអតិថិជន ឬ ក៏អាចកាត់បន្ថយការភ្លេចភ្លាំងលើចំនួនប្រាក់ដែលខាតបង់ ។
- អាចត្រួតពិនិត្យលើការកត់ត្រា និង កាត់បន្ថយឱ្យនៅតិចលើចំនួនប្រាក់ដែលចំណាយខុស ។]

| សកម្មភាពទី៣ : ការសម្ដែងតួអំពីការតាមដានការចំណាយ | ⌚: ៤០ នាទី |
|---|---|

១. គ្រូណែនាំពីខ្លឹមសារការសម្ដែងតួ ៣ ដែលបានសរសេរនៅលើក្រដាសផ្សេងគ្នា (ឬ ឱ្យសិស្សមើលព័ត៌មានដែលមាននៅក្នុងសៀវភៅសិស្ស) ដែលបង្ហាញពីកម្រិតគុណភាពខុសគ្នាក្នុងការអនុវត្តរៀបចំបញ្ជីគណនេយ្យ ។

- ការសម្ដែងតួទី១ : ស្ត្រីម្នាក់មានមុខជំនួញមួយ(ជ្រើសរើសមុខជំនួញមួយដែលក្រុមធ្លាប់ស្គាល់) ។ គាត់មិនធ្លាប់កត់ត្រាពីចំនួនប្រាក់ចំណូល និងចំណាយទេ ។ ថ្ងៃមួយកូនប្រុសរបស់គាត់បានត្រឡប់ពីសាលារៀន ដោយមានសំបុត្រមួយច្បាប់ដែលនាយកសាលាផ្ញើមក ។ សាលាបានស្នើសុំថវិកាខ្លះដើម្បីប្រើការក្នុងដំណើរទស្សនកិច្ចសិក្សារបស់សិស្ស ដែលសាលារៀបចំធ្វើសម្រាប់លើកកម្ពស់កម្មវិធីសិក្សាបំណិនជីវិត ។ រយៈពេល១ខែកន្លងមកហើយដែលសាលារៀនបានផ្សព្វផ្សាយផែនការទស្សនកិច្ចសិក្សានេះ ហើយសមាគមមាតាបិតាសិស្សក៏បានឯកភាពលើផែនការនេះដែរ ។ ស្ត្រីជាម្ដាយមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីរឿងនេះ ។ គាត់ដឹងថាខ្លួនគាត់គ្មានប្រាក់នោះទេ ។ គាត់បានព្យាយាមនឹកគិតពីចំនួនប្រាក់ដែលគាត់រកបានកាលពីសប្ដាហ៍មុន និងចំនួនប្រាក់ដែលគាត់បានចំណាយ ។

- ការសម្ដែងតួទី ២ : ជាងឈើម្នាក់បានលក់ទូមួយឱ្យទៅភ្ញៀវម្នាក់តម្លៃ ១៥០ ០០០ រៀល ។ ពេលមកយកទូភ្ញៀវបានប្រាប់ទៅជាងឈើនោះថា ពេលនេះគាត់មិនបានជាប់ប្រាក់មកជាមួយទេ ប៉ុន្តែគាត់នឹងប្រគល់ប្រាក់ឱ្យនៅចុងខែនេះ ។ នៅចុងខែ ជាងឈើក៏បានទៅទារប្រាក់ពីភ្ញៀវនោះ ។ ភ្ញៀវនោះបាននិយាយថា គាត់ជំពាក់ប្រាក់ថ្លៃទូតែ ១២០ ០០០ រៀលប៉ុណ្ណោះ គាត់មិនឱ្យប្រាក់ទៅជាងឈើលើសពីចំនួន ១២០ ០០០ រៀលនោះឡើយ ។ អាស្រ័យហេតុនេះ ការជជែកដ៏តឹង

តែងក៏កើតមានឡើង។ ប៉ុន្តែជាងឈើគ្មានភស្តុតាងដែលបញ្ជាក់ថាគាត់បានលក់ទូជើក្នុងតម្លៃ ១៥០ ០០០ រៀលនោះទេ ហើយជាងឈើក៏បានសម្រេចចិត្តទទួលយកប្រាក់ថ្លៃលក់ទូតម្លៃ ១២០ ០០០ រៀល។

➢ **ការសម្តែងតួទី៣ :** ស្ត្រីមួយក្រុមរស់នៅក្នុងសហគមន៍ដែលមានឡធ្វើនំមួយ។ ពួកគេបានបែងចែកការងារដូចខាងក្រោម :
- ស្ត្រីម្នាក់ជាអ្នកទទួលខុសត្រូវទិញអុស និង គ្រឿងផ្សំសម្រាប់ធ្វើនំប៉ុង
- ស្ត្រីម្នាក់ត្រូវទទួលខុសត្រូវក្នុងការលក់នំប៉ុង
- ស្ត្រីមួយក្រុមជួយច្របាច់ម្សៅ និង ដុតនំប៉ុង
- ស្ត្រីម្នាក់ជាហិរញ្ញិកដែលទទួលខុសត្រូវក្នុងការទុកដាក់ប្រាក់ឱ្យមានសុវត្ថិភាព

ស្ត្រីដែលជាអ្នកលក់មិនបានកត់ត្រាចំនួនប្រាក់ចំណូលនោះទេ។ ពេលនាងលក់បាននាងប្រគល់ប្រាក់ទៅឱ្យហិរញ្ញិកដើម្បីរៀបចំទុកដាក់នៅក្នុងហិបប្រាក់។ ហិរញ្ញិកជាអ្នកបើកប្រាក់ឱ្យស្ត្រីដែលត្រូវយកទៅទិញអុស និង គ្រឿងផ្សំធ្វើនំប៉ុង។ ហិរញ្ញិកជាមនុស្សម្នាក់ដែលគួរឱ្យទុកចិត្តណាស់ ប៉ុន្តែនាងមិនចេះអក្សរទេ។ នៅចុងខែសមាជិកក្រុមចង់ដឹងពីចំនួនប្រាក់ចំណូលដែលបានមកពីការលក់នំប៉ុង។ នៅពេលបើកហិបប្រាក់ ពួកគេឃើញមានប្រាក់តិចជាងការរំពឹងទុក។ គ្មាននរណាម្នាក់ដឹងថាមានរឿងអ្វីកើតឡើងចំពោះប្រាក់ទាំងនោះឡើយ។ បន្ទាប់ពីពិភាក្សាគ្នាមកពួកគេបានចោទប្រកាន់ស្ត្រីអ្នកលក់នំប៉ុងថាបានលួចប្រាក់មួយចំនួន។

២. គ្រូធ្វើការបែងចែកសិស្សជា ៣ ក្រុម។ ក្រុមនីមួយៗមានពេល១០ នាទី ដើម្បីរៀបចំផែនការ និង ២-៥ នាទីសម្រាប់សម្តែងតួ។ ពួកគេត្រូវជ្រើសរើសតួ និង បង្កើតអត្ថបទសម្តែង។

៣. ក្រុមនីមួយៗមានពេល ៥ នាទី ដើម្បីសម្តែងតួ។ ក្រុមនីមួយៗក៏មានពេល ៥ នាទីផងដែរសម្រាប់ពិភាក្សាលើសំណួរ។

៤. ក្រោយការសម្តែងនីមួយៗ គ្រូត្រូវដឹកនាំសិស្សធ្វើការពិភាក្សាលើការសម្តែង។

➢ **ការសម្តែងទី១ :**(១) តើស្ត្រីនោះមានបញ្ហាអ្វី? (២) តើគាត់គួរធ្វើដូចម្តេចដើម្បីជៀសវាងបញ្ហានោះ?

[**ចម្លើយ:**(**១**) គាត់បានចំណាយប្រាក់ទាំងអស់ ដោយមិនបានគិតពីការបង់វិភាគទានទៅឱ្យសាលារៀនរបស់កូន។ គាត់ថែមទាំងមិនចាំថាតើគាត់បានចំណាយប្រាក់ទៅលើអ្វីនោះទេ។ (**២**) គាត់គួរតែបានកត់ត្រានូវប្រាក់ចំណូល និងចំណាយរបស់គាត់ឱ្យបានត្រឹមត្រូវ និងធ្វើផែនការសម្រាប់បង់វិភាគទានទៅឱ្យសាលារៀន។]

- **ការសម្ដែងទី២ :** (១) ហេតុអ្វីបានជាភ្ញៀវអាចបន្លំថ្លៃលក់ទូរបស់ជាងឈើបាន? (២) តើជាងឈើគួរធ្វើដូចម្ដេចដើម្បីជៀសវាងបញ្ហានេះ?

  [**ចម្លើយ : (១)** ពីព្រោះគាត់គ្មានឯកសារអ្វីជាភស្តុតាងបញ្ជាក់ពីការយល់ព្រមលើតម្លៃ ឬ ចំនួនប្រាក់ដែលភ្ញៀវជំពាក់នោះឡើយ ។ **(២)** ជាងឈើគួរតែធ្វើលិខិតស្នាមដោយមានចុះហត្ថលេខា ឬ ផ្ដិតមេដៃរបស់ភ្ញៀវដែលទិញទូ ។ ]

- **ការសម្ដែងតួទី៣ :** (១) ហេតុអ្វីបានជាសមាជិកក្រុមស្ត្រីនៅឡធ្វើនំប៉ុងខឹង? (២) តើពួកគេគួរធ្វើដូចម្ដេចដើម្បីជៀសវាងបញ្ហាបែបនេះ?

  [**ចម្លើយ : (១)** សមាជិកក្រុមស្ត្រីខឹង ពីព្រោះគ្មាននរណាបានដឹងពីបញ្ហាប្រាក់លក់នំប៉ុង ដែលបាត់នោះឡើយ ។ **(២)** ប្រសិនបើពួកគេមានការកត់ត្រាបានត្រឹមត្រូវនោះ ពួកគេនឹងបានដឹងពីចំនួនប្រាក់ចំណូល និងប្រាក់ចំណាយក្នុងការធ្វើជំនួញរបស់ពួកគាត់ ។ ម្យ៉ាងទៀតការកត់ត្រាពីចំនួនប្រាក់ចំណូល និង ប្រាក់ចំណាយនេះ វាក៏ជួយធ្វើឱ្យពួកគាត់បានដឹងផងដែរ ថាតើការធ្វើជំនួញនេះចំណេញ ឬ ខាត ។]

| សកម្មភាពទី៤ : ការបង្កើតប្រាក់ចំណូល និង ចំណាយក្នុងការធ្វើជំនួញ | ⏲: ១០ នាទី |
|---|---|

**១. ការពិភាក្សា :** គ្រូឱ្យសិស្សលើកឧទាហរណ៍ពីវិធីធ្វើឱ្យមានប្រាក់ចំណូល និង ប្រាក់ចំណាយសម្រាប់ការធ្វើជំនួញ ។ បន្ទាប់មកគ្រូបិទតារាងកត់ត្រានៅលើក្ដារខៀនដូចខាងក្រោម :

| ប្រាក់ចំណាយ | ប្រាក់ចំណូល |
|---|---|
| | |
| (➢ចម្លើយរំពឹងទុក : ផលិតផលដែលខូច ឬ បាត់បង់ ការលក់ជឿ ការចំណាយលើសេវាកម្មធ្យោបាយ ដឹកជញ្ជូនឬសេវាកម្មអ្នកលើកដាក់ ។ល ។) | (➢ចម្លើយរំពឹងទុក : ការលក់ផលិតផល ការបង់ប្រាក់ទិញជឿ ការសងថ្លៃការប្រាក់ ។ល ។) |

# ឯកសារសម្រាប់គ្រូ

| សកម្មភាពទី៥: ការបញ្ចប់មេរៀន | ⏲: ១០ នាទី |
|---|---|

**ការពិភាក្សា :** គ្រូនាំសិស្សធ្វើការពិភាក្សាបញ្ចប់ ដោយសួរសំណួរថា :

- ការឯកភាពលក់វត្ថុជាពាក្យសំដី ឬ មានការកត់ត្រាជាលិខិតស្នាម តើសកម្មភាពណាមួយល្អ? ហេតុអ្វី?
- តើថ្ងៃនេះអ្នកបានរៀនពីអ្វីខ្លះ?
  - [ចម្លើយរំពឹងទុកៈ (១) បញ្ជីគណនេយ្យជាអ្វី។ (២) ហេតុអ្វីបានជាការរៀបចំបញ្ជីគណនេយ្យមានសារៈសំខាន់។ (៣) សារៈប្រយោជន៍ចំពោះការរៀបចំបញ្ជីគណនេយ្យ (៤) ...។ល។]

## មេរៀនទី ២ : តារាងលំហូរសាច់ប្រាក់

⏲ រយៈពេលបង្រៀន ២ ម៉ោង

☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់ ។
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ ។
- គូសតារាងលំហូរសាច់ប្រាក់លើក្រដាសផ្ទាំងធំ២សម្រាប់ប្រើក្នុងសកម្មភាពករណីសិក្សា ។
- សរសេរករណីសិក្សាសកម្មភាពទី ៤ សម្រាប់ ស្រស់ និង សុភាព នៅលើក្រដាសផ្ទាំងធំ ឬ ឱ្យសិស្សមើលព័ត៌មានដែលមាននៅក្នុងសៀវភៅសិស្ស ។
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

📖 សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចបានរៀបរាប់ខាងលើ
- ក្ដារខៀន ដីស និង ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- បំពេញតារាងលំហូរសាច់ប្រាក់ជាគោល ។
- ពិនិត្យមើលកំហុសដែលអាចមាននៅក្នុងតារាងលំហូរសាច់ប្រាក់ ។

**លំនាំនៃការបង្រៀន :**

| សកម្មភាពទី១ : រំលឹកខ្លឹមសារសំខាន់ៗនៃមេរៀនថ្ងៃមុន | ⏲: ១០ នាទី |
|---|---|

ការពិភាក្សា

- ✋ តើការឯកភាពលក់វត្ថុជាពាក្យសំដី ឬ មានការកត់ត្រាជាលិខិតស្នាម តើសកម្មភាពណាមួយល្អ? ហេតុអ្វី?
- ✋ តើបញ្ជីគណនេយ្យជាអ្វី?
- ✋ តើការប្រើប្រាស់បញ្ជីគណនេយ្យមានសារៈប្រយោជន៍ដូចម្ដេចខ្លះ?

**សកម្មភាពទី២ : ការស្វែងយល់ពីរបៀបប្រើប្រាស់តារាងលំហូរសាច់ប្រាក់** ⌚: ១០ នាទី

១. គ្រូបិទតារាងគម្រោងលំហូរសាច់ប្រាក់សម្រាប់ការកត់ត្រាការលំហូរសាច់ប្រាក់ ។

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (−) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ/សេវាកម្ម | ចំនួន | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

២. គ្រូដឹកនាំសិស្សពិភាក្សាពីតារាងលំហូរប្រាក់ ។

- តើក្នុងតារាងមានចំណងជើងអ្វីខ្លះ?
- តើចម្លើយណាខ្លះដែលត្រូវយកទៅដាក់ត្រង់ចំណងជើងនីមួយៗ?

[➢ ចម្លើយរំពឹងទុក

- កាលបរិច្ឆេទ : ថ្ងៃទិញលក់ទំនិញ
- ការទិញលក់ទំនិញ : ប្រភេទសកម្មភាពហិរញ្ញវត្ថុ( ការទិញ ការលក់ ការទិញជឿ និង ការសងប្រាក់ ។
- មុខទំនិញ/សេវាកម្ម : ប្រភេទទំនិញ ឬ សេវាកម្មដែលប្រែប្រួល ។
- បរិមាណ : ចំនួនផលិតផល ឬ សេវាកម្មដែលបានទិញ និង លក់ ។
- តម្លៃលក់រាយ : ថ្លៃលក់សម្រាប់ផលិតផល ១ ឬ ការផ្តល់សេវាកម្ម ១ ។
- ប្រាក់ចំណាយ : ប្រាក់ដែលត្រូវចំណាយទៅលើការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម ។
- ប្រាក់ចំណូល : ប្រាក់ដែលបានទទួលពីការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម ។
- សមតុល្យ : ចំនួនប្រាក់ដែលបានទូទាត់ ( បូក ឬ ដក) រួចសម្រាប់ខ្ទង់ចំណូល ឬ ចំណាយនីមួយៗក្នុងការទិញលក់ទំនិញមួយលើកៗ ។]

# ឯកសារសម្រាប់គ្រូ

| សកម្មភាពទី៣ : ករណីសិក្សារបស់ "ស្រស់" | ⌚: ២០ នាទី |
|---|---|

១. គ្រូបិទករណីសិក្សា **"ស្រស់"** នៅលើជញ្ជាំង ឬ ឱ្យសិស្សមើលករណីសិក្សានៅក្នុងសៀវភៅសិស្ស ។ គ្រូពន្យល់ពីរបៀបបំពេញតារាងលំហូរសាច់ប្រាក់ដោយផ្អែកលើករណីសិក្សារបស់ "ស្រស់ " ។

**ករណីសិក្សារបស់ ស្រស់**

ស្រស់មានបំណង់ធ្វើជំនួញផ្ទាល់ខ្លួននៅផ្សារ ។ នាងមានប្រាក់តែមួយចំនួនតូចប៉ុណ្ណោះ ។ ដូច្នេះនាងចាប់ផ្តើមធ្វើមុខជំនួញតូចមួយ ។ នាងសង្ឃឹមថាមុខជំនួញរបស់នាងនឹងរីកចម្រើន ។

- ស្រស់ចាប់ផ្តើមមុខជំនួញជាមួយនឹងទឹកប្រាក់ចំនួន ៥០ ០០០ រៀល ។
- នៅព្រឹកថ្ងៃទី ២ ខែធ្នូ នាងបានទៅផ្សារ និង បានទិញមុខទំនិញដូចខាងក្រោម :
  - ប៉េងប៉ោះ ៦ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ០០០ រៀល (៦×៣០០០=១៨០០០)
  - ការ៉ុត ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ២០០ រៀល (៤×៣២០០=១២៨០០)
  - ត្រកួន ៨ បាច់ ក្នុង ១ បាច់ថ្លៃ ១ ០០០ រៀល (៨×១០០០=៨០០០)
  - ខ្ទឹមបារាំង ៣ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ១០០ រៀល (៣×៣ ១០០=៩ ៣០០)
  - ម្ទេសហឺរ ៥០ ផ្លែ ថ្លៃ ៧៥០ រៀល
- នៅថ្ងៃនោះនាងបានលក់មុខទំនិញខាងលើក្នុងតម្លៃដូចខាងក្រោម :
  - ប៉េងប៉ោះ ២,៥ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
  - ការ៉ុត ៣ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
  - ត្រកួន ៥ បាច់ ក្នុង ១ បាច់តថ្លៃ ១ ២៥០ រៀល
  - ខ្ទឹមបារាំង ៣ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
  - ម្ទេសហឺរ ៣០ ផ្លែ ក្នុង៥ផ្លែ ថ្លៃ ១០០ រៀល
- នៅរសៀលថ្ងៃទី ២ ខែធ្នូ ដដែលស្រស់បានចំណាយប្រាក់ ៥ ០០០ រៀល ទិញម្ហូបសម្រាប់គ្រួសាររបស់នាង ។
- នៅថ្ងៃទី ៣ ខែធ្នូ ស្រស់ លក់ទំនិញដែលនៅសល់បន្តទៀត ។ ដោយសារមុខទំនិញដែលនៅសល់មិនសូវស្រស់ល្អ នាងលក់ក្នុងតម្លៃថោកជាងមុនបន្តិច ។

  o ប៉េងបោះ ២,៥ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៤០០ រៀល

  o ការ៉ុត ១ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល

  o ត្រកួន ៣ បាច់ ក្នុង ១ បាច់ថ្លៃ ១ ១០០ រៀល

o ម្ទេសហឹរ ១០ ផ្លែ ក្នុង៥ផ្លែ ថ្លៃ ៧៥ រៀល

២. គ្រូដើរពិនិត្យការបំពេញតារាងលំហូរសាច់ប្រាក់របស់សិស្ស :

- គ្រូអានព័ត៌មានស្តីពីការទិញលក់ទំនិញរបស់ស្រស់ឱ្យសិស្សស្តាប់ ។
- គ្រូឱ្យសិស្សម្នាក់អានព័ត៌មានទី១ ស្តីពីការទិញទំនិញ រួចសួរសិស្សថា " តើព័ត៌មាននេះត្រូវកត់ត្រាដាក់នៅកន្លែងណា? " ➢ [ចម្លើយ : នៅក្បែរសមតុល្យលើកដំបូង ។]
- គ្រូសរសេរព័ត៌មាននេះចូលក្នុងតារាង ។
- គ្រូឱ្យសិស្សម្នាក់អានព័ត៌មានទី ២ ស្តីពីការលក់ទំនិញ រួចឱ្យសិស្សម្នាក់ប្រាប់ពីកន្លែងដែលត្រូវបញ្ចូលនៅក្នុងតារាង ។
- នៅពេលសិស្សទាំងអស់ឯកភាព គ្រូឱ្យសិស្សបំពេញព័ត៌មានចូលក្នុងតារាង ។
- គ្រូហៅសិស្សផ្សេងទៀតបំពេញជួរផ្សេងដូចគំរូមុន ។
  - o សិស្សអានចម្លើយរបស់គេ ។
  - o សិស្សទាំងអស់ចូលរួមបញ្ជាក់ពីការយល់ស្រប ។
  - o បន្ទាប់មកសិស្សសរសេរចម្លើយរបស់គេចូលក្នុងតារាង ។
- នៅពេលសិស្សបំពេញចប់ គ្រូសួរសិស្សថា តើប្អូនមានសំណួរអ្វីដែរឬទេ ។

**៣. ពិភាក្សា :**

- តើស្រស់បញ្ចប់ការលក់ដូរដោយទទួលបានប្រាក់ចំណេញ ឬ ខាត? [➢ចម្លើយ : ទទួលបានប្រាក់ចំណេញតិច]
- តើប្រាក់ចំណេញរបស់ស្រស់នៅសល់ប៉ុន្មាន នៅក្នុងប្រអប់សមតុល្យចុងក្រោយ?[➢ចម្លើយ : ១ ៣០០ រៀល]
- តើមុខចំណាយអ្វីដែលស្រស់បានដាក់បញ្ចូលទៅក្នុងតារាងលំហូរសាច់ប្រាក់ដែលមិនមែនជាប្រាក់ចំណាយធ្វើជំនួញ? [ ➢ចម្លើយ : ប្រាក់ចំណាយលើម្ហូបអាហារសម្រាប់គ្រួសារ ។ ការចំណាយប្រភេទនេះមិនត្រូវដាក់បញ្ចូលទៅក្នុងប្រភេទចំណាយធ្វើជំនួញនោះទេ ។ ប្រាក់ចំណាយនេះត្រូវដាក់តារាងប្រាក់ចំណូល និង ចំណាយផ្ទាល់ខ្លួន ។]
- តើប្រាក់ចំណេញពិតប្រាកដរបស់ស្រស់ដែលលក់ក្នុងមួយថ្ងៃប៉ុន្មាន?[ ➢ចម្លើយ: ៦៣០០រៀល ពីព្រោះនាងបានចំណាយ ៥០០០ រៀលទិញម្ហូបសម្រាប់គ្រួសារ ។]
- តើមានមុខទំនិញអ្វីខ្លះដែលស្រស់ត្រូវលក់បន្ត?[ ➢ចម្លើយ : ប៉េងបោះ ១ គីឡូ និង ម្ទេស ១០ ផ្លែ]

☝ តើស្រស់កំពុងតែទទួលបានប្រាក់ចំណេញគ្រប់គ្រាន់សម្រាប់ទ្រទ្រង់មុខជំនួញរបស់នាងដែរឬទេ?

➤ចម្លើយ ៖ ទេ ស្រស់ត្រូវបង្កើនមុខជំនួញបន្ថែមទៀតទើបអាចរកប្រាក់ចំណេញបានគ្រប់គ្រាន់សម្រាប់ការចំណាយរបស់ស្រស់ និង គ្រួសារ ។

☝ តើនាងត្រូវធ្វើដូចម្តេច ដើម្បីបង្កើតឱ្យមានប្រាក់ចំណេញបន្ថែមទៀត? [ ➤ចម្លើយ ៖ ត្រូវលក់ទំនិញឱ្យបានច្រើនមុខបន្ថែមទៀត បង្កើនតម្លៃលក់ឱ្យសមស្រប ។ ស្រស់ត្រូវស្វែងយល់ឱ្យបានច្បាស់ពីតម្រូវការទីផ្សារ និងវិធីទាក់ទាញអតិថិជន ។]

| សកម្មភាពទី៤ ៖ ករណីសិក្សារបស់ សុភ័ក្រ | ⏲: ៣០ នាទី |
|---|---|

១. គ្រូឱ្យករណីសិក្សា "សុភ័ក្រ"ទៅសិស្សអាន ដើម្បីបំពេញតារាងលំហូរសាច់ប្រាក់ ឬ ឱ្យសិស្សមើលសៀវភៅសិស្ស ។

☝ ឱ្យសិស្សចម្លងតារាងលំហូរសាច់ប្រាក់ចូលក្នុងសៀវភៅកត់ត្រារបស់ពួកគេ ប្រសិនបើពួកគេគ្មានសៀវភៅសិស្ស ។

☝ សិស្សបញ្ចូលទិន្នន័យដែលបានពីករណីសិក្សាទៅក្នុងតារាងលំហូរសាច់ប្រាក់ ។

**ករណីសិក្សា ៖ សុភ័ក្រ**

**សុភ័ក្រ** មានបំណងប្រកបមុខរបរលក់ផ្លែឈើ ។ នាងបានខ្ចីប្រាក់ពីពូនាងចំនួន ៣០០ ០០០ រៀល ។ ឪពុកនាងបានឱ្យនាងខ្ចីរទេះដាក់ផ្លែឈើលក់ ។

- **សុភ័ក្រ** ចាប់ផ្តើមប្រកបមុខរបរលក់ផ្លែឈើជាមួយនឹងប្រាក់ ៣០០ ០០០ រៀល ។
- នៅព្រឹកថ្ងៃទី ១ ខែធ្នូ នាងបានទៅមើលតម្លៃផ្លែឈើនៅផ្សារ ។ នៅពេលរសៀលនាងបានសម្រេចចិត្តទិញប្រភេទផ្លែឈើមួយចំនួនដូចខាងក្រោម ៖
  - ផ្លែស្វាយ ៥ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៥ ០០០ រៀល( ៥×៥,០០០=២៥ ០០០)
  - ផ្លែសាវម៉ាវ ៥ គីឡូក្រាម ក្នុង១ គីឡូក្រាមថ្លៃ ៥ ៥០០ រៀល( ៥×៥៥០០=២៧ ៥០០)
  - ក្រូចថ្លុងតូច១៥គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ៥០០រៀល( ១៥×៥ ៥០០=៨២ ៥០០)
  - ផ្លែព័រអាស៊ី ៥ គីឡូ ក្នុង១ គីឡូ ថ្លៃ ៥៦០០ រៀល ( ៥×៥ ៦០០=២៨ ០០០)
  - ផ្លែប៉ោមល្អ ៦ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ១០ ០០០ រៀល ( ៦×១០ ០០០=៦០ ០០០)
- នៅថ្ងៃទី ១ ខែធ្នូ នាងបានទិញកញ្ច្រែង ចំនួន ៥ ដើម្បីដាក់ផ្លែឈើ កញ្ច្រែង ១ ថ្លៃ ១៥ ០០០ រៀល ។

- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ** និង ប្អូនស្រីរបស់នាងបានរុញរទេះផ្លែឈើទៅលក់នៅសួនឧទ្យាន ដែលមានមនុស្ស និង ក្រុមគ្រួសារជាច្រើនមកដើរលេងកំសាន្ត។ ប្រភេទផ្លែឈើដែលនាងលក់មាន ដូចខាងក្រោម ៖
  - ផ្លែស្វាយ ២ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៥ ៥០០ រៀល
  - ផ្លែសារម៉ាវ ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៦ ៣០០ រៀល
  - ក្រូចថ្លុងតូចៗ ១១ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៦ ២០០ រៀល
  - ផ្លែព័រអាស៊ី ៣ គីឡូ ក្នុង១ គីឡូ ថ្លៃ ៦ ៣០០ រៀល
  - ផ្លែប៉ោមល្អ ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ១៥ ០០០ រៀល
- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ**បានឱ្យប្រាក់ទៅប្អូនស្រីរបស់នាងចំនួន ៤ ០០០ រៀល សម្រាប់ការជួយរុញរទេះរបស់នាង។
- នៅថ្ងៃទី ២ ខែធ្នូ **សុភ័ក្រ**បានបន្តលក់ផ្លែឈើដែលនៅសល់តែម្នាក់ឯងនៅតាមដងផ្លូវ។ ប៉ុន្តែដោយសារផ្លែឈើដែលនៅសល់មិនសូវស្រស់ នាងលក់តម្លៃថោកជាងមុនបន្តិច។
  - ផ្លែស្វាយ ថ្លៃ ៥ ២០០ រៀល ក្នុង១ គីឡូក្រាម
  - ផ្លែសារម៉ាវ ថ្លៃ ៥ ៤០០ រៀល ក្នុង១ គីឡូក្រាម
  - ក្រូចថ្លុងតូចៗ ថ្លៃ ៥ ៣០០ រៀល ក្នុង១ គីឡូក្រាម
  - ផ្លែព័រអាស៊ី ថ្លៃ ៦ ០០០ រៀល ក្នុង១ គីឡូក្រាម
  - ផ្លែប៉ោមល្អ លក់តម្លៃដដែល។

២. គ្រូទុកពេលឱ្យសិស្ស ២០ នាទី បំពេញតារាងលំហូរសាច់ប្រាក់ជាបុគ្គលនៅក្នុងសៀវភៅកត់ត្រារបស់ពួកគេ។

៣.គ្រូឱ្យសិស្សឡើងបំពេញតារាងលំហូរសាច់ប្រាក់ដែលមាននៅលើក្រដាសផ្ទាំងធំ ជាជំហានៗ ដោយប្រើព័ត៌មានក្នុងករណីសិក្សារបស់ សុភ័ក្រ។

៤. ការពិភាក្សាពីករណីសិក្សារបស់ សុភ័ក្រ

- ☝ តើការធ្វើជំនួញរបស់សុភ័ក្រកំពុងតែទទួលបានប្រាក់ចំណេញឬខាត?[ ➢ចម្លើយ៖ ទេនាងខាតប្រាក់ចំនួន ៣៤ ៥០០ រៀល ពេលចាប់ផ្តើមជំនួញដំបូង។]
- ☝ តើហេតុអ្វីបានជានាងលក់ផ្លែឈើខាតនៅថ្ងៃនេះ?[ ➢ចម្លើយ៖ សុភ័ក្របានចំណាយប្រាក់ទិញកញ្ច្រែងអស់មួយចំនួន សម្រាប់ដាក់ផ្លែឈើ។ នាងត្រូវទិញទំនិញណាដែលមានតម្លៃថោក ហើយនាងអាចលក់បានថ្លៃជាងនេះ ស្របតាមតម្លៃទីផ្សារ។]
- ☝ តើសុភ័ក្រនឹងបានប្រាក់ចំណូលប៉ុន្មានពីការលក់ បើមិនគិតបញ្ចូលថ្លៃទិញកញ្ច្រែង?[ ➢ចម្លើយ៖ ៤០ ០០០ រៀល]

- ប្រសិនបើសុភ័ក្របន្តមានចំនួនប្រាក់ចំណូល និង ចំណាយដដែល តើនាងត្រូវលក់ប៉ុន្មានដងទើបរួច ថ្លៃទិញកញ្ច្រែង? [ ➢ចម្លើយ : នាងត្រូវលក់ទំនិញមួយលើកទៀតទើបអាចរួចថ្លៃទិញកញ្ច្រែង ។]
- តើអ្នកមានយោបល់អ្វីសម្រាប់ជួយធ្វើឱ្យមុខជំនួញរបស់សុភ័ក្ររីកចម្រើន? [ ➢ចម្លើយ : អាស្រ័យលើចម្លើយរបស់សិស្ស ។]
- តើអ្នកគិតថាមុខជំនួញរបស់ស្រស់ ឬ សុភ័ក្រ អាចនឹងរីកចម្រើននៅពេលអនាគតដែរឬទេ? ហេតុអ្វី? [ ➢ចម្លើយ : ឥឡូវនេះមុខជំនួញរបស់សុភ័ក្រមានលក្ខណៈល្អប្រសើរជាង ។ សិស្សអាចផ្តល់គំនិតបានច្រើនទាក់ទង នឹងមូលហេតុនេះ ។]

**សកម្មភាពទី៥ : ការរៀបចំសម្រាប់ធ្វើសម្ភាសជាមួយអ្នកធ្វើជំនួញ** ⏲: **១០ នាទី**

១. គ្រូពន្យល់ :

សម្រាប់មេរៀនលើកក្រោយប្អូននឹងត្រូវធ្វើការសម្ភាសជាមួយអ្នកធ្វើជំនួញម្នាក់ដែលអញ្ជើញមកពីសហគមន៍ ដើម្បីបង្ហាញពីបទពិសោធន៍នៃការកត់ត្រាប្រាក់ចំណូល និង ចំណាយ ។

២. នេះជាសំណួរសំខាន់ៗមួយចំនួន ដែលយើងត្រូវប្រើ ដើម្បីសួរអ្នកធ្វើជំនួញមកពីសហគមន៍ ។ ចូរសរសេរសំណួរទាំងនេះនៅក្នុងសៀវភៅកត់ត្រា ។

➢ តើប្រព័ន្ធនៃការរៀបចំបញ្ជីគណនេយ្យដែលបង/ពូ/មីង/អ៊ំប្រើមានអ្វីខ្លះ?

➢ តើមានការប្រឈមអ្វីខ្លះដែលពួកគេជួបប្រទះក្នុងការរៀបចំបញ្ជីគណនេយ្យ?

➢ តើប្រភេទប្រាក់ចំណូល និង ចំណាយ( ការលក់ទំនិញ ប្រាក់កម្ចី ការទិញជឿ ការចំណាយលើកិច្ចការសេវាកម្ម) អ្វីខ្លះដែលគេត្រូវតាមដាន?

➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធមិនល្អដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យ បានដែរឬទេ?

➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធៗល្អដែលគេធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

៣. ចូរជ្រើសរើសសំណួរមួយចំនួនក្នុងចំណោមសំណួរផ្ទាល់ខ្លួនរបស់អ្នកដែលបានបង្កើតនៅពេលចាប់ផ្តើមមេរៀនដំបូង ដើម្បីដាក់បន្ថែមទៅក្នុងបញ្ជីសំណួរសម្ភាស ។

៤. អ្នកអាចសួរសំណួរទៅអ្នកធ្វើជំនួញដែលមកពីសហគមន៍ ។ សិស្សដទៃទៀតអាចចូលរួមក្នុងការសម្ភាសនោះ ។

៥. គ្រូណែនាំសិស្សឱ្យសរសេរសំណួរបន្ថែម ២ ទៀតដែលពួកគេចង់សួរនៅពេលគេត្រឡប់ទៅផ្ទះ ។

**កិច្ចការផ្ទះ**

# ឯកសារសម្រាប់គ្រូ

១. គ្រូឱ្យសិស្សបង្កើតសំណួរយ៉ាងតិច២ ដើម្បីត្រៀមសួរទៅអ្នកជំនួញម្នាក់នៅក្នុងសហគមន៍អំពីការរៀបចំបញ្ជីគណនេយ្យ ។

➲ គ្រូត្រូវចាំថានៅពេលបង្រៀនលើកក្រោយ គ្រូត្រូវរៀបចំអញ្ជើញមនុស្ស ម្នាក់ ឬ ២ នាក់មក ថ្នាក់រៀន ដើម្បីផ្តល់បទពិសោធន៍ពីការរៀបចំបញ្ជីគណនេយ្យ ។ អ្នកធ្វើជំនួញនោះអាចជា អ្នកទិញ និង ជាអ្នកលក់ ឬ អ្នកផ្តល់សេវាកម្មអ្វីមួយ ។ អ្នកធ្វើជំនួញនេះអាចជាអ្នកលក់ដូរនៅក្នុងសាលា អ្នកលក់ដូរ នៅតាមផ្ទះ នៅតាមផ្សារ នៅតាមភោជនីយដ្ឋាន ឬ ជាងឈើ ។ល ។

ចម្លើយករណីសិក្សារបស់ស្រស់

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៥០ ០០០ |
| ២/១២/០៨ | ការទិញទំនិញ | ប៉េងប៉ោះ | ៦គីឡូក្រាម | ៣ ០០០ | ១៨ ០០០ | | ៣២ ០០០ |
| | | ការ៉ុត | ៤គីឡូក្រាម | ៣ ២០០ | ១២ ៨០០ | | ១៩ ០០០ |
| | | ត្រកួន | ៨បាច់ | ១ ០០០ | ៨ ០០០ | | ១១ ២០០ |
| | | ខ្ទឹមបារាំង | ៣គីឡូក្រាម | ៣ ១០០ | ៩ ៣០០ | | ១ ៩០០ |
| | | ម្ទេស | ៥០ផ្លែ | ៧៥០ | ៧៥០ | | ១ ១៥០ |
| ២/១២/០៨ | ការលក់ទំនិញ | ប៉េងប៉ោះ | ២.៥ | ៣ ៥០០ | | ៨ ៧៥០ | ៩ ៩០០ |
| | | ការ៉ុត | ៣ | ៣ ៥០០ | | ១០ ៥០០ | ២០ ៤០០ |
| | | ត្រកួន | ៥ | ១ ២៥០ | | ៦ ២៥០ | ២៦ ៦៥០ |
| | | ខ្ទឹមបារាំង | ៣ | ៣ ៥០០ | | ១០ ៥០០ | ៣៧ ១៥០ |
| | | ម្ទេស | ៣០ | ១០០ក្នុង៥ ផ្លែ | | ៦០០ | ៣៧ ៧៥០ |
| ២/១២/០៨ | របស់របរផ្គត់ផ្គង់ក្នុងគ្រួសារ | ម្ហូប | | | ៥ ០០០ | | ៣២ ៧៥០ |
| ៣/១២/០៨ | ការលក់ទំនិញ | ប៉េងប៉ោះ | ២.៥ | ៣ ៤០០ | | ៨ ៥០០ | ៤១ ២៥០ |
| | | ការ៉ុត | ១ | ៣ ៥០០ | | ៣ ៥០០ | ៤៤ ៧៥០ |
| | | ត្រកួន | ៣ | ១ ១០០ | | ៣ ៣០០ | ៤៨ ០៥០ |
| | | ម្ទេស | ១០ | ៧៥ក្នុង៥ផ្លែ | | ១៥០ | ៤៨ ៣០០ |

ចម្លើយករណីសិក្សារបស់សុភ័ក្ត្រ

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៣០០ ០០០ |
| ១/១២/០៨ | ការទិញទំនិញ | ផ្លែស្វាយ | ៥ គីឡូក្រាម | ៥ ០០០ | ២៥ ០០០ | | ២៧៥ ០០០ |
| | | សាវម៉ាវ | ៥ គីឡូក្រាម | ៥ ៥០០ | ២៧ ៥០០ | | ២៤៧ ៥០០ |
| | | ផ្លែក្រូច | ១៥ គីឡូក្រាម | ៥ ៥០០ | ៨២ ៥០០ | | ១៦៥ ០០០ |
| | | ផ្លែព័រ | ៥ គីឡូក្រាម | ៥ ៦០០ | ២៨ ០០០ | | ១៣៧ ០០០ |
| | | ផ្លែប៉ោម | ៦ គីឡូក្រាម | ១០ ០០០ | ៦០ ០០០ | | ៧៧ ០០០ |
| ១/១២/០៨ | ការទិញសម្ភារ | កញ្ជ្រែង | ៥ | ១៥ ០០០ | ៧៥ ០០០ | | ២ ០០០ |
| ១/១២/០៨ | ការលក់ទំនិញ | ផ្លែស្វាយ | ២ | ៥ ៥០០ | | ១១ ០០០ | ១៣ ០០០ |
| | | ផ្លែសាវម៉ាវ | ៤ | ៦ ៣០០ | | ២៥ ២០០ | ៣៨ ២០០ |
| | | ផ្លែក្រូច | ១១ | ៦ ២០០ | | ៦៨ ២០០ | ១០៦ ៤០០ |
| | | ផ្លែព័រ | ៣ | ៦ ៣០០ | | ១៨ ៩០០ | ១២៥ ៣០០ |
| | | ផ្លែប៉ោម | ៤ | ១៥ ០០០ | | ៦០ ០០០ | ១៨៥ ៣០០ |
| ១/១២/០៨ | បង់ថ្លៃឈ្នួលរុញរទេះ | ថ្លៃឈ្នួលរុញរទេះ | ១ | ៤ ០០០ | ៤ ០០០ | | ១៨១ ៣០០ |
| ២/១២/០៨ | ការលក់ទំនិញ | ផ្លែស្វាយ | ៣ | ៥ ២០០ | | ១៥ ៦០០ | ១៩៦ ៩០០ |
| | | ផ្លែសាវម៉ាវ | ១ | ៥ ៤០០ | | ៥ ៤០០ | ២០២ ៣០០ |
| | | ផ្លែក្រូច | ៤ | ៥ ៣០០ | | ២១ ២០០ | ២២៣ ៥០០ |
| | | ផ្លែព័រ | ២ | ៦ ០០០ | | ១២ ០០០ | ២៣៥ ៥០០ |
| | | ផ្លែប៉ោម | ២ | ១៥ ០០០ | | ៣០ ០០០ | ២៦៥ ៥០០ |

## មេរៀនទី៣ : ការស្វែងយល់ពីការអនុវត្តបញ្ជីគណនេយ្យ

រយៈពេលបង្រៀន ២ ម៉ោង

☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យខ្លឹមសារសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរសម្រាប់សកម្មភាពដែលត្រូវរៀន
- រៀបចំ និង អញ្ជើញអ្នកជំនួញ ២ នាក់នៅក្នុងសហគមន៍មកចូលរួមផ្ដល់បទពិសោធនៅក្នុងថ្នាក់
- សរសេរសំណួរសម្ភាសនៅលើក្រដាសផ្ទាំងធំ (ប្រសិនបើសិស្សមានសៀវភៅហើយមិនបាច់សរសេរទេ)
- សរសេរការណែនាំស្ដីពីការប្រកាន់ឥរិយាបថល្អនៅពេលធ្វើសម្ភាសដាក់លើក្រដាសផ្ទាំងធំ សម្រាប់ប្រើនៅសកម្មភាពទី ៣ (ប្រសិនបើសិស្សមានសៀវភៅ ពួកគេអាចមើលខ្លឹមសារនេះនៅក្នុងសៀវភៅ) ។
- កម្រងសំណួរ និងខ្លឹមសារមេរៀន

សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចបានរៀបរាប់ខាងលើ
- ក្រដាសផ្ទាំងធំ ហ្វឺត និង ក្ដារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ ដែលប្រើនៅក្នុងសកម្មភាពទី ២ ។
- ក្ដារខៀន និង ដីស
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ធ្វើតារាងបង្ហាញពីឥរិយាបថសមស្របសម្រាប់ប្រើក្នុងការធ្វើសម្ភាស
- ធ្វើសម្ភាសជាមួយអ្នកជំនួញដែលមកពីក្នុងសហគមន៍
- កំណត់ព័ត៌មានសំខាន់ៗក្នុងការធ្វើសម្ភាសដែលអាចផ្ដល់ជាមធ្យោបាយសម្រាប់ឱ្យគេយកទៅអនុវត្តក្នុងការរៀបចំបញ្ជីគណនេយ្យឱ្យបានល្អប្រសើរ ។

លំនាំនៃការបង្រៀន :

| សកម្មភាពទី១ : ការរំលឹកមេរៀន | ◷: ១០ នាទី |
|---|---|

**ការពិភាក្សា :**

☞ តើអ្នកបានរៀនអ្វីខ្លះកាលពីមេរៀនមុន?[ ➢ចម្លើយ : ការបំពេញតារាងលំហូរសាច់ប្រាក់ ។]

☞ តើការប្រើប្រាស់តារាងលំហូរសាច់ប្រាក់មានប្រយោជន៍អ្វីខ្លះ?[ ➢ចម្លើយ : ធ្វើឱ្យមានការកត់ត្រាពីចំនួនប្រាក់ចំណូល និងចំណាយបានត្រឹមត្រូវនៅក្នុងកិច្ចការជំនួញ ។]

| សកម្មភាពទី២ : ការបង្កើតសំណួរសម្ភាស | ◷: ២០ នាទី |
|---|---|

១. គ្រូប្រាប់សិស្សថាគាត់បានអញ្ជើញអ្នកធ្វើជំនួញនៅក្នុងសហគមន៍មកកាន់ថ្នាក់រៀនដើម្បីធ្វើសម្ភាស ។

២. គ្រូពន្យល់ទៅសិស្សថា :

- នៅថ្ងៃនេះ យើងត្រូវសម្ភាសអ្នកជំនួញ ម្នាក់ ឬ ២ នាក់ដែលអញ្ជើមមកពីសហគមន៍ ដើម្បីស្វែងយល់ពីរបៀបរៀបចំ បញ្ជីគណនេយ្យសម្រាប់កិច្ចការជំនួញ ។
- ពេលទៅផ្ទះវិញអ្នកត្រូវបង្កើតសំណួរ ២ ដើម្បីសួរ អ្នកជំនួញទាំងនេះ ។
- យើងមិនមានពេលគ្រប់គ្រាន់សម្រាប់សួរសំណួរទាំងអស់ទៅពួកគាត់ នោះទេ ដូចនេះយើងត្រូវជ្រើសរើសសំណួរសំខាន់ៗ មួយចំនួនប៉ុណ្ណោះសម្រាប់សួរ ។

៣. គ្រូបិទតារាងសំណួររបស់គាត់ដូចខាងក្រោម នៅលើក្ដារខៀនឱ្យសិស្សពិនិត្យ និង ប្រៀបធៀប

➢ តើប្រព័ន្ធនៃការរៀបចំបញ្ជីគណនេយ្យដែលអ្នកប្រើមានអ្វីខ្លះ?

➢ តើបញ្ហាប្រឈមអ្វីខ្លះដែលពួកគេធ្លាប់ជួបប្រទះក្នុងការរៀបចំបញ្ជីគណនេយ្យ?

➢ តើប្រភេទប្រាក់ចំណូល និង ចំណាយ( ការលក់ទំនិញ ប្រាក់កម្ចី ការទិញជឿ ការចំណាយលើកិច្ចការសេវាកម្ម) អ្វីខ្លះដែលគេត្រូវតាមដាន?

➢ តើពួកគាត់អាចប្រាប់ពីបទពិសោធមិនល្អនៅពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

➢ តើពួកគាត់អាចប្រាប់ពីបទពិសោធល្អនៅពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

៤. គ្រូបែងចែកសិស្សជាក្រុមដែលមានគ្នាពី៥-៦ នាក់ ដើម្បីពិនិត្យសំណួរឡើងវិញ ។

- ក្រុមនីមួយៗត្រូវជ្រើសរើសសំណួរ ២ ដែលសំខាន់សម្រាប់សួរ
- សិស្សត្រូវសរសេរសំណួរទាំងពីរនៅលើក្រដាសតូច
- គ្រូឱ្យតំណាងក្រុមនីមួយៗអានសំណួរទាំង២

- គ្រូឱ្យសិស្សជ្រើសរើសសំណួរដែលពួកគេត្រូវសួរអ្នកធ្វើជំនួញមកពីសហគមន៍ ។

៥. អ្នកត្រូវចាំមិនអាចសួរសំណួរឱ្យលើសពី ៨ បានទេ ។

៦. ឱ្យសិស្សស្ម័គ្រចិត្តម្នាក់សួរសំណួរសម្ភាសទៅអ្នកជំនួញមកពីសហគមន៍ ។ បន្ទាប់មកសិស្សផ្សេងទៀតអាចចូលរួមក្នុងការសម្ភាសនេះ ។ គ្រូត្រូវកំណត់សិស្សដែលត្រូវសួរសំណួរ ។

| សកម្មភាពទី ៣ : ការប្រកាន់ឥរិយាបថសមរម្យពេលធ្វើសម្ភាស | ⌚: **១០ នាទី** |
|---|---|

១. របៀបប្រកាន់ឥរិយាបថល្អពេលធ្វើសម្ភាស :

- សុភាពរាបសារ និង ចេះគួរសម
- ធ្វើការណែនាំខ្លួន
- ប្រាប់ពីគោលបំណងនៃការសម្ភាស
- សុំការអនុញ្ញាតពីអ្នកធ្វើជំនួញ ២ ឬ ៣ នាទី ដើម្បីសម្ភាស
- ថ្លែងអំណរគុណពេលសម្ភាសចប់ ។

២. គ្រូឱ្យសិស្សបង្ហាញពីឥរិយាបថល្អផ្សេងៗទៀត ដើម្បីដាក់បន្ថែម ។

៣. គ្រូឱ្យសិស្សស្ម័គ្រចិត្ត ២ នាក់ សម្តែងពីការប្រកាន់ឥរិយាបថល្អ និង អាក្រក់ក្នុងពេលធ្វើសម្ភាស ដោយគ្រូដើរតួធ្វើជាភ្ញៀវ ។

៤. សិស្សផ្សេងទៀតរៀបចំកន្លែងទទួលភ្ញៀវ និង ធ្វើការកត់ត្រាក្នុងពេលធ្វើសម្ភាស ។

| សកម្មភាពទី ៤ : ការធ្វើសម្ភាសជាមួយអ្នកជំនួញមកពីសហគមន៍ | ⌚:៤០ នាទី |
|---|---|

១. ភ្ញៀវបានអញ្ជើញមកដល់ ។

២. គ្រូទទួលស្វាគមន៍ភ្ញៀវឱ្យចូលថ្នាក់ និង ធ្វើការណែនាំភ្ញៀវដល់សិស្សដោយប្រាប់ពី :

- ឈ្មោះរបស់ពួកគាត់
- ប្រភេទមុខជំនួញដែលពួកគាត់ធ្វើ
- ទីកន្លែងធ្វើជំនួញរបស់ដើម្បីគាត់

៣. គ្រូរៀបចំសិស្សដើម្បីសម្ភាសតាមសកម្មភាពដូចខាងក្រោម :

- សិស្សត្រូវសួរសំណួរទៅកាន់ភ្ញៀវម្នាក់ម្តង
- សិស្សសម្ភាសភ្ញៀវទាំង ២ នាក់ រួមគ្នាក្នុងពេលតែមួយ

# ឯកសារសម្រាប់គ្រូ

- គ្រូបែងចែកសិស្សជា ២ ក្រុម ហើយរៀបចំទីកន្លែង ២ ដាច់ដោយឡែកពីគ្នាសម្រាប់ការសម្ភាសភ្ញៀវម្នាក់ៗ ។ប្រសិនមានពេលគួរឱ្យសិស្សធ្វើការសង្ខេបពីលទ្ធផលសម្ភាសនៅក្នុងក្រុមនីមួយៗ និងពិភាក្សាលំអិតពីចម្លើយនៃសំណួរនីមួយៗ និង ចំណុចសំខាន់ៗ ។

១. នៅពេលចប់ការសម្ភាស គ្រូត្រូវថ្លែងអំណរគុណភ្ញៀវ និង សួរទៅភ្ញៀវក្រែងពួកគាត់មានពាក្យពេចន៍ផ្តាំផ្ញើទៅសិស្ស ។

២. ពេលភ្ញៀវចេញទៅ ប្រសិនបើនៅសល់ម៉ោង នោះសិស្សអាចធ្វើការពិភាក្សាពីអ្វីដែលបានឮក្នុងពេលធ្វើសម្ភាស ហើយពិនិត្យឡើងវិញពីចម្លើយនៃសំណួរនីមួយៗ ។

## មេរៀនទី៤ : ការកំណត់តម្លៃទំនិញ

⌚ រយៈពេលបង្រៀន ២ ម៉ោង

☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរនិយមន័យនៃប្រាក់ចំណេញ ប្រាក់ចំណូល និង ការខាត់បង់សម្រាប់សកម្មភាពទី ២
- សរសេរសំណួរលើក្រដាសផ្ទាំងធំសម្រាប់ផ្នែកទី២ នៅសកម្មភាពទី ១ ( ប្រសិនបើសិស្សមានសៀវភៅ គ្រូអាចឱ្យសិស្សមើលសៀវភៅរបស់គេ) ។
- កាត់ក្រដាសជាចម្រៀកតូចៗសម្រាប់សកម្មភាពទី ៣
- កម្រងសំណួរ និងខ្លឹមសារមេរៀន

📖 សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស( ជាជម្រើសដែលគ្រូអាចត្រូវការបើចាំបាច់)
- រៀបចំសម្ភារៈបង្រៀនដូចដែលបានកំណត់ខាងលើ
- ក្រដាសផ្ទាំងធំស្ដីពីការប្រកាន់តំរិយាបថល្អពេលធ្វើសម្ភាស
- ក្រដាសផ្ទាំងធំ ហ្វឺត និង ក្ដារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ ។
- ក្ដារខៀន និង ដីស
- ឡាំងតូច ប្រអប់ មួកសម្រាប់ដាក់ជំរាកក្រដាសតូចៗ
- កម្រងសំណួរ និងខ្លឹមសារមេរៀន

✡ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់និយមន័យប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាតបង់ នៅក្នុងការរៀបចំបញ្ជីគណនេយ្យ
- បំពេញតារាងលំហូរសាច់ប្រាក់សម្រាប់ការធ្វើជំនួញ
- ធ្វើតារាងលំហូរប្រាក់ដែលប៉ាន់ប្រមាណបានទូវការកំណត់តម្លៃលក់ ។

លំនាំនៃការបង្រៀន :

| សកម្មភាពទី១ : ពិនិត្យឡើងវិញលើលទ្ធផលដែលបានពីការសិក្សានៅមេរៀនមុន | ⌚: ១០ នាទី |
|---|---|

១- ការពិភាក្សា : គ្រូនាំសិស្សពិភាក្សាសំណួរខាងក្រោម :

- តើអ្នកបានរកឃើញសារៈសំខាន់អ្វីខ្លះទាក់ទងនឹងការធ្វើសម្ភាស?
- តើអ្នកបានរៀនអ្វីខ្លះពីការរៀបចំបញ្ជីគណនេយ្យល្អ ឬ ការអនុវត្តមុខជំនួញសម្រាប់ប្រកបមុខរបរនៅពេលអនាគត?
- តើក្នុងពេលសម្ភាសមានចំណុចអ្វីខ្លះដែលអ្នកគិតថាមិនសំខាន់ ឬ មិនមានប្រយោជន៍សម្រាប់ការអនុវត្ត?
- តើអ្នកមានសំណួរអ្វីបន្ថែមដែលអ្នកមិនបានសួរ ប៉ុន្តែអ្នកនៅតែចង់ដឹងដែរឬទេ?

| **សកម្មភាពទី២ : ការស្វែងយល់ពីប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាតបង់** | **⌚: ២០ នាទី** |
|---|---|

១. គ្រូសួរសិស្សថា "តើពាក្យថាប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាតមានន័យដូចម្តេច ?

២. បន្ទាប់មកគ្រូបិទនិយមន័យនៃពាក្យទាំងនេះនៅលើក្តារខៀន និង ពន្យល់បញ្ជាក់បន្ថែម រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ ។

[➢ **ចម្លើយរំពឹងទុក :**

➢ **ប្រាក់ចំណូល** ជាប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម

➢ **ប្រាក់ចំណេញ** ជាប្រាក់ដែលនៅសល់ពីការទូទាត់រវាងប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម ជាមួយប្រាក់ដែលបានចំណាយទៅលើការទិញទំនិញ ឬការផ្តល់សេវាកម្មក្នុងការធ្វើជំនួញ ។ ប្រាក់ចំណេញខុសពីប្រាក់ចំណូល ។

➢ **ប្រាក់ខាត** ជាប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្តល់សេវាកម្មដែលមានចំនួនតិចជាងប្រាក់ដែលបានចំណាយទៅលើការទិញទំនិញ ឬការផ្តល់សេវាកម្មក្នុងការធ្វើជំនួញ ។ ក្នុងករណីនេះអ្នកនៅតែមានប្រាក់ចំណូល ប៉ុន្តែវាជាប្រាក់ចំណូលដែលតិចជាងប្រាក់ចំណាយ ។]

៣.តើប្រាក់ចំណូល និង ប្រាក់ចំណេញខុសគ្នាដូចម្តេច?

[ ➢ចម្លើយ : ប្រាក់ចំណូលជាចំនួនប្រាក់សរុបទាំងអស់ដែលបានមកពីការធ្វើជំនួញ ។ ប្រាក់ចំណេញជាប្រាក់ដែលនៅសល់ក្រោយពីការទូទាត់រួចពីការចំណាយទាំងអស់ ។]

៤. គ្រូពន្យល់ពីខ្លឹមសារមេរៀនដូចខាងក្រោម ៖

មេរៀននេះគឺជាការស្វែងយល់ពីភាពខុសគ្នារវាងប្រាក់ចំណូល និង ជាការបង្ហាញ ឱ្យដឹងពីការធ្វើជំនួញចំណេញ ឬ ខាត ។ ប្រសិនបើមុខជំនួញរបស់អ្នកកំពុងតែទទួលបានប្រាក់ចំណេញ អ្នកមានឱកាសក្នុងការពង្រីកមុខជំនួញ និងមានប្រាក់សម្រាប់ចំណាយផ្ទាល់ខ្លួនទៀតផង ។ ប្រសិនបើអ្នកខាត អ្នកមិនអាចទ្រទ្រង់ជីវភាពមិនអាចសងបំណុលគេ ហើយប្រាក់ផ្ទាល់ខ្លួនត្រូវកាត់បន្ថយមិនអាចមានលទ្ធភាពបន្តមុខជំនួញបានទេ ។

៥. គ្រូបង្ហាញពីគោលបំណងនៃមេរៀននេះ ។

**សកម្មភាពទី៣ ៖ ការកំណត់តម្លៃ** ⏲: ៣០ នាទី

១. ក្រុមសិស្សបង្កើតតារាងស្តីពីប្រភេទមុខជំនួញសំខាន់ៗនៅតាមទីផ្សារក្នុងមូលដ្ឋាន ។ គ្រូគួរសរសេរឈ្មោះមុខជំនួញទាំងនេះ នៅលើក្រដាសតូចដោយឡែកពីគ្នា ។ ប្រសិនបើមុខជំនួញណាមិនចាំបាច់គ្រូមិនបាច់បញ្ចូលក្នុងតារាងទេ ។ (ចម្លើយរំពឹងទុក៖ ការលក់ផ្លែឈើ ការលក់បន្លែ រត់ម៉ូតូឌុប ការលក់គុយទាវ ការលក់គ្រឿងតុទូ ។ល ។) ត្រូវរកឧទាហរណ៍ឱ្យបានពី ៦-១០ ។

២. គ្រូមូរក្រដាសទាំងនេះ រួចដាក់ចូលទៅក្នុងឡាំងតូច (កញ្ជ្រែង ឬ មួក ឬ ប្រអប់)

៣. គ្រូបែងចែកសិស្សជាក្រុមតូចមានគ្នា ៤-៥ នាក់ និង ពន្យល់ដូចខាងក្រោម ៖

- តារាងមុខជំនួញដែលយកចេញពីប្រអប់ ត្រូវបំពេញសញ្ញា“+” សម្រាប់ ប្រាក់ចំណេញ និង សញ្ញា “-” សម្រាប់ប្រាក់ចំណាយ ហើយក្រុមសិស្សត្រូវចាំថាការធ្វើជំនួញ គឺមានការប្រែប្រួលជានិច្ច ។ គ្រូត្រូវចងចាំពីទម្រង់នៃការប្រើតារាងនេះ ។

| -ប្រាក់ចំណាយ | +ប្រាក់ចំណូល |
|---|---|
| | |

- ពិនិត្យចំនួនប្រាក់ដែលចំណាយទៅលើមុខទំនិញ ឬ ការផ្តល់សេវាកម្ម យើងអាចសាកល្បងទាយពីតម្លៃដែលយើងត្រូវលក់ផលិតផលខាងលើ ។
- ទាក់ទងនឹងវិធីកំណត់តម្លៃទំនិញ ជាដំបូងសិស្សត្រូវសាកល្បងប៉ាន់តម្លៃលក់ដុំនៅផ្សារជាមុនសិន មុនពេលពួកគេធ្វើការកំណត់តម្លៃមុខទំនិញនីមួយៗ ដែលគេនឹងត្រូវលក់ ។

- សិស្សត្រូវប្រើព័ត៌មានទាំងនេះ ដើម្បីកំណត់តម្លៃមុខទំនិញ ឬ សេវាកម្មដែលសមស្របចំពោះមុខទំនិញនៅក្នុងសហគមន៍ដែលគ្រូបានកំណត់ឱ្យ ។

៤. គ្រូដើរពិនិត្យក្រុមសិស្សធ្វើការ និង ទុកឱកាសឱ្យក្រុមនីមួយៗយកក្រដាសមុខជំនួញចេញពីប្រអប់មកពិនិត្យ និងពិភាក្សាគ្នា ។

| សកម្មភាពទី ៤: ការប្រមូលព័ត៌មានពីតម្លៃទំនិញ | ⌚: ២០ នាទី |
|---|---|

១. គ្រូឱ្យសិស្សចូលក្រុមតូចរបស់គេដដែល ។

២. គ្រូឱ្យក្រុមសិស្សធ្វើកិច្ចការបន្ថែមមួយទៀតគឺការធ្វើសម្ភាសជាមួយអ្នកលក់ដូរ ២ នាក់នៅផ្សារចំពោះមុខទំនិញ ឬ សេវាកម្មដែលគេបានជ្រើសរើស ។

៣. ពួកគេនឹងត្រូវរៀបចំសម្ភាសអ្នកលក់ដូរយ៉ាងតិចឱ្យបាន ២ នាក់ នៅផ្សារ ដើម្បីប្រមូលព័ត៌មានអំពីតម្លៃលក់ទំនិញ ។ គ្រូនឹងផ្តល់សំណួរសម្ភាសមួយចំនួនឱ្យប្អូនធ្វើហើយប្អូនត្រូវបង្កើតសំណួរបន្ថែមទៀតនៅក្នុងក្រុមតូចរបស់ប្អូន ។

២. នេះជាសំណួរមួយចំនួនដែលអ្នកប្រើសម្រាប់ធ្វើសម្ភាស ចូរសរសេរសំណួរទាំងនេះនៅក្នុងសៀវភៅកត់ត្រារបស់ប្អូន ឬ មើលនៅក្នុងសៀវភៅសិស្ស :

- តើទំនិញដែលអ្នកលក់មានតម្លៃប៉ុន្មាន?
- ជាធម្មតាតើអ្នកឱ្យថ្លៃប៉ុន្មាន?
- តើអ្នកបានកំណត់តម្លៃលក់ដោយរបៀបណា?
- តើតម្លៃលក់មានការប្រែប្រួលដែរឬទេក្នុងមួយឆ្នាំៗ? ហេតុអ្វី?
- តើការលំបាកអ្វីខ្លះដែលអ្នកជួបប្រទះក្នុងការកំណត់តម្លៃ?
- ជានិច្ចកាលតើអ្នកទទួលបានប្រាក់ចំណេញក្នុងការលក់ដែរឬទេ? បើមិនចំណេញ តើមកពីមូលហេតុអ្វីខ្លះ?
- តើអ្នកធ្វើដូចម្តេច ដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវអ្នក?

៥. ទុកឱកាសឱ្យក្រុមតូចពិនិត្យមើលសំណួរឡើងវិញ និង បង្កើតសំណួរ ១ ឬ ២ ផ្សេងទៀតដែលពួកគេចង់សួរអ្នកលក់ ។

# ឯកសារសម្រាប់គ្រូ

៦. ការពិភាក្សា៖ គ្រូឱ្យក្រុមសិស្សទាំងអស់មករួមគ្នាវិញ ដើម្បីពិភាក្សាពីសំណួរ ដែលសិស្សបានបង្កើតនៅតាមក្រុមតូច ។

៧. គ្រូរំលឹកសិស្សក្រុមតូចទាំងអស់ថាត្រូវប្រកាន់ឥរិយាបថសុភាពរាបសារក្នុងពេលធ្វើសម្ភាស ។

## កិច្ចការផ្ទះ

១. ដឹកនាំការធ្វើសម្ភាស ២ និង ធ្វើការកត់ត្រាពេលធ្វើសម្ភាស ។

២. កត់ត្រាចម្លើយដែលបានមកពីការធ្វើសម្ភាសសម្រាប់ឱ្យគ្រូពិនិត្យ ។

៣. សិស្សធ្វើការជាក្រុម ដើម្បីធ្វើការបង្ហាញខ្លីមួយរយៈពេល ៥ នាទី ជាមួយសិស្សក្នុងថ្នាក់ដោយសង្ខេបពីខ្លឹមសារនៃការសម្ភាស ។

## មេរៀនទី៥ : ការស្វែងយល់ពីការកំណត់តម្លៃទំនិញ

⏲ រយៈពេលបង្រៀន ២ ម៉ោង

☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់។
- ពិនិត្យខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរសំណួរនៅលើក្រដាសផ្ទាំងធំសម្រាប់ផ្នែកទី២ នៅសកម្មភាពទី ១។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅ។
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

🕮 សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស(ជាជម្រើសដែលគ្រូអាចត្រូវការបើចាំបាច់)
- សម្ភារៈបង្រៀនដូចដែលមានរៀបរាប់នៅខាងលើ
- ក្រដាសផ្ទាំងធំស្តីពីការប្រកាន់ឥរិយាបថល្អពេលធ្វើសម្ភាស
- ក្រដាសផ្ទាំងធំ ហ្វឺត និង ក្ដារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ
- ក្ដារខៀន និង ដីស
- ឡាំងតូច ប្រអប់ មួកសម្រាប់ដាក់ជំរាកក្រដាសតូចៗ
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- សម្ភាសជាមួយអ្នកលក់ដូរនៅតាមផ្សារក្នុងមូលដ្ឋាន
- បង្ហាញពីលទ្ធផលនៃការសម្ភាសដល់សិស្សទាំងអស់នៅក្នុងថ្នាក់
- ប្រើបទពិសោធន៍នៃការសម្ភាសតាមផ្សារ ដើម្បីគណនាពីតម្លៃពីលើកមុន
- ពន្យល់ពីគុណសម្បត្តិ និង គុណវិបត្តិមុខជំនួញតាមផ្សារ
- លើកឡើងយ៉ាងតិចនូវវិធី ៣ ដែលអ្នកលក់ប្រើដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវ

លំនាំនៃការបង្រៀន :

| សកម្មភាពទី១ : ការបង្ហាញលទ្ធផលនៃការសម្ភាសស្តីពីការកំណត់តម្លៃ | 🕑: ៤០ នាទី |
|---|---|

១- គ្រូឱ្យសិស្សចូលទៅតាមក្រុមតូចគេ ហើយទុកឱកាស ២០ នាទីដើម្បីរៀបចំការបង្ហាញ ។ ចែកក្រដាសផ្ទាំងធំឱ្យក្រុមនីមួយៗសម្រាប់រៀបចំការបង្ហាញ ។

២- ក្រុមសិស្សធ្វើការបង្ហាញលទ្ធផលនៃការធ្វើសម្ភាសរបស់ពួកគេ ។

- តើពួកគេបានទៅសម្ភាសជាមួយអ្នកណា?
- តើទំនិញ ឬសេវាកម្មរបស់ពួកគេមានអ្វីខ្លះ?
- សង្ខេបចម្លើយដែលគេបានសួរនៅពេលធ្វើសម្ភាស ។
- តាមរយៈការធ្វើសម្ភាស តើអ្នកជឿថាតម្លៃទំនិញរបស់អ្នកត្រឹមត្រូវ និង សមហេតុផលដែរឬទេ ប្រសិនបើអ្នកជាអ្នកលក់ទំនិញនៅផ្សារ?ចូរពន្យល់ ។
- តើការទិញលក់ទំនិញរបស់អ្នកសម្ភាសមានដាក់បញ្ចូលការកំណត់តម្លៃណាមួយ ដែលក្រុមរបស់អ្នកមិនបានធ្វើដែរឬទេ?
- តើបច្ចេកទេសអ្វីខ្លះដែលពួកគេប្រើដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវ?

| សកម្មភាពទី ២ : ការវាយតម្លៃឡើងវិញពីការកំណត់តម្លៃរបស់យើង | 🕑: ២០ នាទី |
|---|---|

១. គ្រូទុកឱកាសឱ្យសិស្សពិភាក្សាក្នុងក្រុមតូច ដើម្បីធ្វើការវាយតម្លៃឡើងវិញលើការសម្រេចចិត្ត ពីការបំពេញសញ្ញា “+” និង “-” នៅក្នុងតារាង ស្តីពីប្រាក់ចំណូល និង ប្រាក់ចំណាយ និង ការកំណត់តម្លៃ ។

- តើតម្លៃលក់របស់អ្នកស្ថិតនៅក្រោម ឬ នៅលើអត្រាតម្លៃលក់នៅទីផ្សារ?
- ផ្អែកលើការសម្ភាស តើអ្នកគួរកែប្រែព័ត៌មាននៅក្នុងតារាងប្រាក់ចំណូល និង ប្រាក់ចំណាយ របស់អ្នកដែរឬទេ?
- តើក្រុមរបស់អ្នកគួរតែគណនាឡើងវិញពីតម្លៃលក់ទំនិញ ឬ សេវាកម្មរបស់អ្នក ដើម្បីធ្វើឱ្យមានប្រាក់ចំណេញ និង មានលក្ខណៈប្រកួតប្រជែងតម្លៃដែរឬទេ?
- ប្រសិនបើត្រូវគណនាតម្លៃទំនិញ ចូរធ្វើកិច្ចការនេះឡើងវិញ ។
- តើមានគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះចំពោះមុខជំនួញនៅតាមទីផ្សាររបស់អ្នក? (➢ចម្លើយរំពឹងទុក : កើតមានតាមរដូវកាល ទទួលបានប្រាក់ចំណេញតិចតួច មានការប្រែប្រួលតម្លៃក្នុងទីផ្សារ មិនមានតម្រូវការគ្រប់គ្រាន់)

| សកម្មភាពទី ៣ : ការពិភាក្សាការវាយតម្លៃឡើងវិញពីការកំណត់តម្លៃរបស់យើង | : ២០ នាទី |
|---|---|

១. ការពិភាក្សា : គ្រូដឹកនាំសិស្សពិភាក្សាលើចំនុចដូចខាងក្រោម :

- តើមានប៉ុន្មានក្រុមដែលធ្វើការកំណត់តម្លៃលក់ស្ថិតនៅក្រោមតម្លៃលក់នៅទីផ្សារ? ចូរពន្យល់ ។
- តើមានប៉ុន្មានក្រុមដែលធ្វើការកំណត់តម្លៃលក់ស្ថិតនៅលើតម្លៃលក់នៅទីផ្សារ? ចូរពន្យល់ ។
- តើមានប៉ុន្មានក្រុមដែលបានសំរេចចិត្តកែប្រែការកំណត់តម្លៃលក់? ចូរពន្យល់ពីមូលហេតុ ។
- តើអ្នកគិតថាមុខជំនួញនៅទីផ្សាររបស់អ្នកកំពុងតែបង្កើនប្រាក់ចំណូល និង នៅតែមានលក្ខណៈប្រកួតប្រជែងដែរឬទេ?
- ចូរលើកពីគុណសម្បត្តិ និង គុណវិបត្តិមួយចំនួននៃការប្រកបមុខជំនួញនៅទីផ្សារ ។
- តើមានវិធីសាស្ត្រអ្វីខ្លះដែលអ្នកចង់អនុវត្តតាម ដើម្បីទាក់ទាញ និង រក្សាភ្ញៀវ?

## មេរៀនទី៦ ៖ ការពិនិត្យប្រាក់អាប់

⏱ រយៈពេលបង្រៀន ២ ម៉ោង

☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យខ្លឹមសារសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេររបៀបគណនាចំនួនប្រាក់អាប់នៅលើក្រដាសផ្ទាំងធំ ឬ ថតចម្លងសន្លឹកកិច្ចការនេះសម្រាប់ចែកឱ្យសិស្ស។ (ប្រសិនបើសិស្សមានសៀវភៅគេអាចមើល ខ្លឹមសារទាំងនេះនៅក្នុងសៀវភៅ) ។
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

📖 សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស (ជាជម្រើសដែលគ្រូអាចត្រូវការបើចាំបាច់)
- សម្ភារៈដូចដែលមានរៀបរាប់ខាងលើ
- ក្តារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- កំណត់បានកំហុសដែលច្រើនកើតមាននៅពេលអាប់ប្រាក់ក្នុងពេលទិញនិងពេលលក់ទំនិញ
- គណនាប្រាក់អាប់បានត្រឹមត្រូវនៅពេលទិញនិងពេលលក់ទំនិញ

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១ ៖ សេចក្តីផ្តើម | ⏱ **៣០ នាទី** |
|---|---|

**ការពិភាក្សា ៖** គ្រូឱ្យសិស្សពិភាក្សាពីសំណួរដូចខាងក្រោម ៖

- ✋ តើអ្នកធ្លាប់អាប់ប្រាក់ឱ្យគេ ឬ ទទួលប្រាក់អាប់ពីគេខុសដែរឬទេ?
- ✋ ចូរនិយាយពីបទពិសោធន៍របស់អ្នកទាក់ទងនឹងការអាប់ប្រាក់នេះ ។
- ✋ តើប្រភេទរូបិយវត្ថុអ្វីខ្លះដែលកំពុងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា?(**ចម្លើយរំពឹងទុក៖** ប្រាក់បាតថៃ ១ បាត= ៣៤ រៀល / ១ ដុល្លារអាមេរិក=៤ ០០០ រៀល ឬ ៤ ១០០រៀល)
- ✋ សិស្សលើកឧទាហរណ៍ ឬរឿងទាក់ទងនឹងបទពិសោធនៃការអាប់ប្រាក់ច្រឡំនេះ?

(**ចម្លើយរំពឹងទុក:** ការប្តូរពីប្រាក់រៀលទៅប្រាក់ ដុល្លារ ការទិញទំនិញច្រើន ការចាកចេញទៅដោយមិនបានរាប់ប្រាក់អាប់) ។

| | |
|---|---|
| **សកម្មភាពទី២ : លំហាត់អនុវត្តស្តីពីការប្រឈមនឹងការអាប់ប្រាក់** | **៣០ នាទី** |

១. គ្រូនឹងត្រូវផ្តល់ឱ្យសិស្សនូវលំហាត់ចំនួន ៥ ដើម្បីឱ្យពួកគេអនុវត្តគណនាការអាប់ប្រាក់ ។

១. **រតនា** បានទៅផ្សារ ដើម្បីទិញគ្រឿងបន្លាស់ម៉ូតូ ។ គាត់បានទិញសំបកកង់ថ្មីចំនួន ១ កាំកង់ថ្មីសម្រាប់ដាក់កង់ម៉ូតូរបស់គាត់ ឈ្នាន់សម្រាប់ដាក់ជើង និងកញ្ចក់២ ។ អ្នកលក់បានកំណត់ថ្លៃសម្រាប់មុខទំនិញទាំងនេះដូចតទៅ : សំបកកង់ថ្លៃ ១៣.៥០ ដុល្លារ កាំកង់ម៉ូតូថ្លៃ ១ ដុល្លារ កញ្ចក់ ២ថ្លៃ ៣ ដុល្លារ និងឈ្នាន់ដាក់ជើង២ថ្លៃ ៤ ដុល្លារ ។

គាត់បានតថ្លៃអ្នកលក់សម្រាប់មុខទំនិញទាំងអស់ឱ្យត្រឹមតែ ១៩.៥០ ដុល្លារ ។

ក. តើរតនាបានតថ្លៃទំនិញចុះបានប៉ុន្មានភាគរយ?

ខ. គាត់បានឱ្យប្រាក់ទៅអ្នកលក់ចំនួន ៨០ ០០០ រៀល ។ តើអ្នកលក់ត្រូវអាប់ប្រាក់ឱ្យគាត់ប៉ុន្មាន ប្រសិនបើអត្រាប្តូរប្រាក់ ១ ដុល្លារ= ៤០៥០ រៀល?

គ. តើអ្នកលក់ត្រូវអាប់ប្រាក់ឱ្យគាត់ប៉ុន្មាន ប្រសិនបើអត្រាប្តូរប្រាក់ ១ ដុល្លារ= ៤១០០ រៀល?

**ចម្លើយរំពឹងទុក :**

ក១. តម្លៃទំនិញសរុបមិនទាន់តថ្លៃគឺ: 13.5+1+3+4=21.5

ក២. $19.5 ÷ 21.5=0.907; 1.0-0.907=0.093×100=9.3%

ខ. $19.5 × 4050៛ = 78 975 ៛ ។ ចម្លើយគឺប្រាក់អាប់មានចំនួន 1000៛ (នៅសល់ 25 ៛)

គ. $19.5 ×4100= 79 950 ។ ចម្លើយគឺប្រាក់អាប់នៅសល់តិចពេកមិនអាចយកជាការបាន (នៅសល់ 50 ៛) ។

២. **ចាន់ថា** បានទៅផ្សារទិញគ្រឿងផ្សំដើម្បីញាំត្រយូងចេក ។ ជាធម្មតាគាត់ធ្វើញាំត្រយូងចេកដោយប្រើគ្រឿងផ្សំដូចតទៅ : ត្រយូងចេក (១ ៥០០ រៀល) បង្គារក្រៀម(៥ ០០០ រៀល) សាច់មាន់(៨ ០០០ រៀល) ជីរ (៥០០ រៀល) និង ទឹកត្រី (២ ០០០ រៀល) ។ ម្យ៉ាងទៀតនៅផ្ទះគាត់មានភ្ញៀវចូលមកបន្ថែម ដូចនេះ គាត់ត្រូវទិញគ្រឿងផ្សំទ្វេដង ។ គាត់បានចំណាយទៅលើថ្លៃជិះម៉ូតូទៅផ្សារ ១ ៥០០ រៀល និងត្រឡប់មកវិញ ១ ៥០០រៀល ។ គាត់មានប្រាក់ចំនួន ១០ ដុល្លារអាមេរិក ។ អ្នកលក់បានអាប់ប្រាក់ឱ្យគាត់ក្នុងអត្រា ១ ដុល្លារអាមេរិក= ៤ ០៥០ រៀល ។

ក. តើ**ចាន់ថា**មានប្រាក់ចំនួនប៉ុន្មានសម្រាប់ទៅផ្សារ?

ខ. តើគាត់នៅសល់ប្រាក់ចំនួនប៉ុន្មានក្រោយពីទិញទំនិញ?

**ចម្លើយរំពឹងទុក:**

ក. (1500 × 2)+ (5000 × 2)+ (8000×2)+(500×2)+(2000×2)+(1500×2)=37 000 ឬ

(1500+5000+8000+500+2000) ×2+(1500×2)=37 000 ។

ខ. ១០ ដុល្លារអាមេរិក × ៤០៥០ រៀល=៤០ ៥០០ រៀល ; ៤០ ៥០០-៣៧ ០០០= ៣ ៥០០ រៀល

៣. **វីរត្ន** បានចំណាយប្រាក់រៀបចំអាហារថ្ងៃត្រង់ ដើម្បីអបអរនឹងការឡើងតំណែងការងារថ្មីមិត្តភក្តិរបស់គាត់។ គាត់បានធ្វើដំណើរទៅតាមភោជនីយដ្ឋានមួយចំនួន ដើម្បីពិនិត្យមើលតម្លៃត្រូវចំណាយសម្រាប់អាហារថ្ងៃត្រង់។ គាត់បានយល់ព្រមនឹងម្ចាស់ភោជនីយដ្ឋានម្នាក់ ក្នុងការនាំមិត្តភក្តិរបស់គាត់មកហូបអាហារថ្ងៃត្រង់នៅទីនេះ ដោយម្ចាស់ហាងបានចុះតម្លៃឱ្យគាត់ចំនួន ៥%។ **វីរត្ន** បានហៅមុខម្ហូបដូចតទៅ : ម្ហូរសាច់គោ ២ចាន(១ចាន ថ្លៃ ៥ ដុល្លារ) ត្រីស្ងោរ ១ចាន(ថ្លៃ ៤,៥០ ដុល្លារ) មាន់ឆាខ្ញី ៣ចាន(១ ចានថ្លៃ ៣ ដុល្លារ) ឆាត្រកួនប្រេងខ្យង ២ចាន(១ចានថ្លៃ ១,៥០ ដុល្លារ) ឆាបន្លែសាច់ជ្រូក ២ចាន(១ចានថ្លៃ ៣ដុល្លារ) បង្គារអាំង ៣ចាន(១ចានថ្លៃ ៥ដុល្លារ) មឹកឆាជាមួយម្រេច ២ចាន(១ចានថ្លៃ ៤,៥០ដុល្លារ)។ ពួកគេក៏បានហៅទឹកសុទ្ធ ២ដប (១ដបថ្លៃ១,៥០ដុល្លារ) និងស្រាបៀរ ៥ កំប៉ុង(១កំប៉ុងថ្លៃ ១ដុល្លារ)។**វីរត្ន** បានឱ្យប្រាក់ទៅម្ចាស់ ចំនួន ៣០០ ០០០ រៀល។

តើម្ចាស់ហាងត្រូវអាប់ប្រាក់ឱ្យ **វីរត្ន**ចំនួនប៉ុន្មាន ប្រសិនបើអត្រាប្តូរប្រាក់ ១ដុល្លារ=៤ ១០០ រៀល?

**ចម្លើយរំពឹងទុក**

តម្លៃពិតនៅក្នុងបញ្ជីមុខម្ហូប : (២× ៥ ដុល្លារ)+(១× ៤,៥០ ដុល្លារ)+(៣× ៣ ដុល្លារ)+(២× ១,៥០ ដុល្លារ)+(២× ៣ ដុល្លារ)+(៣× ៥ ដុល្លារ)+(២× ៤,៥០ ដុល្លារ)+(២× ១,៥០ ដុល្លារ)+(៥× ១ ដុល្លារ)
=៦៤,៥ ដុល្លារ

តម្លៃសរុបគិតជាប្រាក់រៀល : ៦៤,៥០ ដុល្លារ ×៤ ១០០ រៀល= ២៦៤ ៤៥០ រៀល

ចំនួនប្រាក់ដែលបានចុះថ្លៃ : ២៦៤ ៤៥០រៀល ×0,0៥ = ១៣ ២២២,៥ រៀល

តម្លៃសរុបដែលត្រូវបង់: ២៦៤ ៤៥០រៀល-១៣ ២២២,៥០ រៀល = ២៥១ ២២៧,៥ រៀល

ចំនួនប្រាក់អាប់: ៣០០ ០០០រៀល- ២៥១ ២២៧,៥ រៀល= ៤៨ ៧៧២,៥ រៀល

៤. **លឿត** ត្រូវបានមិត្តភក្តិអញ្ជើញឱ្យទៅចូលរួមពិធីរៀបអាពាហ៍ពិពាហ៍មួយ ។ នាងមិនច្បាស់ទេថាតើនាងគួរចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ឬ ផ្ញើប្រាក់ចងដៃ ។ នាងសន្សំបានប្រាក់ចំនួន ៦០ ដុល្លារ ។ ប្រសិនបើនាងទៅចូលរួមនាងត្រូវចំណាយប្រាក់(២០០ ០០០ រៀល) សម្រាប់ទិញសំលៀកបំពាក់ ចំណាយប្រាក់ ១០ ០០០ រៀល ធ្វើសក់និងតុបតែងខ្លួន ចំណាយប្រាក់ ១៥ ០០០រៀល ធ្វើក្រចកដៃនិងក្រចកជើង ហើយត្រូវចងដៃកូនក្រមុំកូនកំលោះ ២០ ០០០ រៀល ទៀត ។ អត្រាប្តូរប្រាក់ ៤ ១០០ រៀល ក្នុង ១ ដុល្លារ ។

ក. បើផ្អែកលើការរៀបរាប់ពីចំណាយតើ**លឿត**អាចមានប្រាក់គ្រប់គ្រាន់សម្រាប់ទៅចូលរួមក្នុងពិធីរៀបការនោះបានឬទេ? ចូរពន្យល់ ។

ខ. ប្រសិនបើនាង **លឿត** មិនទៅចូលរួមក្នុងពិធីរៀបការនោះ តើនាងអាចផ្ញើប្រាក់ចងដៃប៉ុន្មាន?

**ចម្លើយរំពឹងទុក :**

តម្លៃសរុប: (២០០ ០០០+១០ ០០០+១៥ ០០០+២០ ០០០=២៤៥ ០០០ រៀល

អត្រាប្តូរប្រាក់៤ ១០០ : ២៤៥ ០០០ ÷ ៤ ១០០ = ៥៩,៧៦ ដុល្លារ

ក. បើអត្រាប្តូរប្រាក់មានតម្លៃ ១ ដុល្លារ=៤ ១០០ រៀល នាង**លឿត**អាចទៅចូលរួមពិធីរៀបការនោះបាន តែនាងត្រូវចំណាយប្រាក់សន្សំរបស់នាងទាំងអស់ ។

ខ. វិធីមួយទៀតគឺ នាង **លឿត** ត្រូវពិចារណាពីជម្រើសមិនទៅចូលរួមក្នុងពិធីរៀបការនោះ
តែផ្ញើប្រាក់ឱ្យគេចងដៃឱ្យវិញ ។

៥. **លី** បានទទួលប្រាក់បាតថៃចំនួន ៣៥០បាត ពីមីងរបស់នាងពេលដែលគាត់មកលេងផ្ទះ។ នាង លី សប្បាយចិត្តណាស់ ព្រោះនាងត្រូវការសម្ភារៈសិក្សា និងស្បែកជើងថ្មីមួយគូផងដែរ។ នាងបានទៅប្តូរប្រាក់ ក្នុងអត្រាប្តូរប្រាក់១បាត=១១៥ រៀល។ ពេលប្តូរបានហើយជាដំបូងនាងបានទៅទិញស្បែកជើងថ្មី ១គូ តម្លៃ២៨ ០០០ រៀល។ បន្ទាប់មក នាងបានទៅកន្លែងលក់សម្ភារៈសិក្សាដើម្បីទិញ ប៊ិច និងសៀវភៅសរសេរខ្លះ។ នាងចង់ទុកប្រាក់ចំនួន ៤ ០០០ រៀល សម្រាប់ទិញនំផ្ញើម្តាយនាង។

តើ **លី** អាចទិញសៀវសរសេរ និង ប៊ិច បានចំនួនប៉ុន្មាន ប្រសិនបើប៊ិច ១ ថ្លៃ ១ ៨០០ រៀល និង សៀវភៅ១ក្បាលថ្លៃ ១ ៣០០ រៀល?

**ចម្លើយរំពឹងទុក ៖**

ចំនួនប្រាក់សរុបដែលបានដូរ ៖ ៣៥០ បាត ×១១៥ រៀល = ៤០ ២៥០ ៛

ប្រាក់នៅសល់ពីទិញស្បែកជើង ៖ ៤០ ២៥០ - ២៨ ០០០ = ១២ ២៥០ ៛

ប្រាក់ដែលនៅសល់សម្រាប់ទិញសៀវភៅ និងប៊ិច ៖ ១២ ២៥០-៤ ០០០ = ៨ ២៥០

ចំនួនប៊ិច និង សៀវវភៅដែលអាចទិញ ៖

- នាងអាចទិញបានសៀវភៅ ៤ក្បាល និង ប៊ិច ១ ដើម ហើយនៅសល់ប្រាក់ ១ ២៥០ រៀល។
- នាងអាចទិញបានសៀវភៅ ៣ក្បាល និង ប៊ិច ២ ដើម ហើយនៅសល់ប្រាក់ ៧៥០ រៀល។
- នាងអាចទិញបានសៀវភៅ ២ក្បាល និង ប៊ិច ៣ ដើម ហើយនៅសល់ប្រាក់ ២៥០ រៀល។

២. សិស្សធ្វើការជាដៃគូ ហើយប្តូរសៀវភៅលំហាត់របស់គេជាមួយសិស្សផ្សេងទៀត ដើម្បីពិនិត្យមើលពីការគណនាចំនួនប្រាក់អាប់។

៣. គ្រូដើរពិនិត្យមើលការគណនាចំនួនប្រាក់អាប់របស់ដៃគូសិស្សនីមួយៗ។

៤. គ្រូឱ្យសិស្សលើកឧទាហរណ៍ទាក់ទងនឹងបទពិសោធនៃការទិញទំនិញណាមួយ រួចឱ្យសិស្សផ្សេងទៀតធ្វើការគណនារកចំនួនប្រាក់អាប់ដែលនៅសល់។

៥. **ការពិភាក្សា ៖** គ្រូសួរទៅសិស្សថា តើពួកគេមានការប្រឈមអ្វីខ្លះទាក់ទងនឹងការគណនារកចំនួនប្រាក់អាប់ដែលនៅសល់ក្នុងមេរៀននេះ។

# ឯកសារសម្រាប់គ្រូ

**សកម្មភាពទី៣: ការសង្ខេបលើខ្លឹមសារនៃឯកសារណែនាំ** ⌚ ២០ នាទី

**ការពិភាក្សា :** គ្រូឱ្យសិស្សពិភាក្សាដើម្បីសង្ខេបខ្លឹមសារមេរៀនស្តីពី ការរៀបចំបញ្ជីគណនេយ្យ ។ សិស្សអាចឆ្លើយនឹងសំណួរទាំងនេះដែលមាននៅក្នុងសៀវភៅរបស់គេ ។

- តើនរណាអាចប្រាប់ពីសារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យ?
- ចូរប្រាប់ឈ្មោះប្រភេទចំណូលចំណាយក្នុងការធ្វើជំនួញ ។
- ចូរលើកឧទាហរណ៍ពីការអនុវត្តល្អ និង ការអនុវត្តមិនល្អពេលប្រើប្រាស់ប្រាក់ក្នុងការធ្វើជំនួញ ។
- ប្រាប់ពីការប្រកាន់ឥរិយាបថល្អមួយចំនួននៅពេលធ្វើសម្ភាស?
- ចូរប្រាប់ឈ្មោះមនុស្សមួយចំនួន ដើម្បីសួរយោបល់ និងព័ត៌មានពីការរៀបចំបញ្ជីគណនេយ្យសម្រាប់ធ្វើជំនួញនៅពេលអនាគត ។ ប្រាប់ពីមូលហេតុ ដែលអ្នកជ្រើសរើសមនុស្សនោះ ។
- ចូរប្រាប់ពីអត្ថន័យនៃពាក្យ " ប្រាក់ចំណូល " " ប្រាក់ចំណេញ " និង " ប្រាក់ខាត "
- តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីកំណត់តម្លៃទំនិញ?
- តើហេតុអ្វីបានជាចាំបាច់ត្រូវធ្វើការគណនាតម្លៃទំនិញឱ្យបានច្បាស់លាស់?
- តើវិធីសាស្ត្រអ្វីខ្លះដើម្បីទាក់ទាញ និង រក្សាភ្ញៀវ?
- តាមគំនិតរបស់អ្នក តើចំណុចអ្វីដែលគួរឱ្យចាប់អារម្មណ៍ខ្លាំងបំផុត និង អាចជួយអ្នកអាចធ្វើសកម្មភាពដែលអ្នកបានរៀន និង ពេលធ្វើសម្ភាស?

## ឧបសម្ព័ន្ធ ១.១ : ទម្រង់ប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

### ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ________ សាលា ________ ភេទ ______ ក្រុម ______ ថ្នាក់ទី ____ ប្រភេទ ______

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| វិញ្ញាសាទី ១: [illegible] | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ (បើពិន្ទុ ០ ដល់ ៧-ខ្សោយ/ បើ ៨ ដល់ ១០-មធ្យម / បើ ១១ ដល់ ១៥-ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | **ពិន្ទុ (១-៥)** | **និទ្ទេស** |
| ១ | [illegible] | | |
| ២ | [illegible] | | |
| ៣ | [illegible] | | |
| ៤ | [illegible] | | |
| ៥ | [illegible] | | |
| ៦ | [illegible] | | |
| ៧ | [illegible] | | |
| | សរុបសង្កេតឥរិយាបថសិស្ស | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ ០ ដល់ ១៧ -ខ្សោយ/ បើ ១៨ ដល់ ២៣-មធ្យម / បើ ២៤ ដល់ ៣៥-ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ ០ ដល់ ២៤-ខ្សោយ/ បើ ២៥ ដល់ ៣៣-មធ្យម / បើ ៣៤ ដល់ ៥០-ល្អ) | | | |

ថ្ងៃទី ...... ខែ ...... ឆ្នាំ ......

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបវាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក ........................សាលា ............................... ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | | ការវាយតម្លៃគ្រូបំណិនជីវិត |
|---|---|---|---|---|---|
| សាលា | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិតៈ |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយសម្ភារត្រៀមជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន? | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេ** | **1-2-3-4-5** | |
| **ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀន ដោយមានតួនាទីក្រុមច្បាស់លាស់** | **1-2-3-4-5** | |
| **រីករាយជាមួយមេរៀនដែលគ្រូបង្រៀន** | **1-2-3-4-5** | |
| **បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន** | **1-2-3-4-5** | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **អនុវត្តតាមកិច្ចតែងការដែលមាន?** | **1-2-3-4-5** | ***សូមបញ្ជាក់ពាក្យណាមួយដែលត្រូវបានប្រើ*** |
| **ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ជាក់ស្តែង?** | **1-2-3-4-5** | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម ឧ.ដៃគូ គំនិត, ករណីសិក្សា, ការសម្តែងតួ,ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេល វេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និង បង្កើនទំនុកចិត្តរបស់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែល មានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយ តម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន ហើយធ្វើការស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំងៗ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសន្ទនា។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខានិងឈ្មោះរបស់អ្នកវាយតម្លៃ ....................

ហត្ថលេខានិងឈ្មោះរបស់គ្រូ ..................................

# ជំនាញទីផ្សារសាមញ្ញៗ



ដាក់ទុនមួយចំណែកនៃប្រាក់ចំណេញរបស់អ្នកទៅក្នុងគម្រោងយួរអង្វែងមួយ។ កុំចំណាយទាំងអស់ទៅលើការសប្បាយ ចូរសន្សំមួយចំណែកដើម្បីការរកស៊ី និងមួយចំណែកសម្រាប់ការចំណាយដែលមិនបានរំពឹងទុក។

*ហេតុអ្វីអ្នកគួរសន្សំមួយចំណែកនៃប្រាក់ចំណេញរបស់យើងសម្រាប់ការរកស៊ី?*



ត្រូវមានភាពច្នៃប្រឌិត។ ជៀសវាងអ្វីដែលមនុស្សភាគច្រើនធ្វើដោយចំណាយពេលតិច។

*ភាពចង់កែម៉ូតូឌុប ប៉ុន្តែនៅក្នុងភូមិមានអ្នកកែម៉ូតូឌុប ១០នាក់ហើយ។ តើនេះជាគំនិតល្អដែរឬទេ?*



ធ្វើការស្រាវជ្រាវ **មុនពេលអ្នកចាប់ផ្ដើមសហគ្រាសថ្មីមួយ**

*តើខ្ញុំអាចដឹងថាតើផលិតផលណាពេញនិយមនៅក្នុងភូមិរបស់ខ្ញុំដោយរបៀបណា?*



ស្វែងរកជំនួយសម្រាប់ផែនការជំនួញរបស់អ្នក។ រកមនុស្សណាដែលអាចជួយអ្នក និងមានចំណេះដឹងទាក់ទងនឹងផែនការរបស់អ្នក។

*តើវាល្អគ្រប់គ្រាន់ទេ ប្រសិនបើខ្ញុំសុំដំបូន្មានតែពីគ្រួសាររបស់ខ្ញុំ?*



ស្វែងរកដៃគូក្នុងជំនួញរបស់អ្នកអាចបង្កើនប្រាក់ចំណេញ។ ត្រូវធ្វើកិច្ចព្រមព្រៀងឲ្យបានច្បាស់លាស់។

*២ឆ្នាំមុន វុទ្ធីបាននិយាយជាមួយដៃគូរបស់គាត់អំពីកិច្ចសន្យា។ ដៃគូជំនួញរបស់គាត់មិនចង់ធ្វើវាទេ។ វុទ្ធីមិនច្បាស់។ តើអ្នកនឹងធ្វើបែបណា?*



ជំនួញខ្លះត្រូវការប្រាក់ដើមទុនមុនពេលអ្នកចាប់ផ្ដើម។ ត្រូវគិតថ្លៃដើមផលិតផលទាំងអស់ និងពិភាក្សាពីការកម្ចីមួយដែលអាចមានជាមួយមនុស្សដែលអ្នកអាចទុកចិត្តបាន។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារគឺជាជម្រើសដ៏ល្អ។

*ហេតុអ្វីបានជាធនាគារជាជម្រើសដ៏ប្រសើរជាងការខ្ចីប្រាក់ពីប្រធានភូមិ?*



តម្លៃថោកមិនមែនមានន័យថាតែងតែជាជម្រើសដ៏ល្អនោះទេ។ អ្នកទិញដឹងពីបញ្ហានេះ។ ផលិតផលមានគុណភាព និងថ្លៃដើមទាបគឺជាធាតុគន្លឹះ។

*តើយុទ្ធសាស្ត្រអ្វីដែលអ្នកអាចគិតឃើញដើម្បីធ្វើឲ្យប្រាកដថាទទួលបានថ្លៃដើមទាប?*



ចូរប្រាកដជាមួយគុណភាពគ្រប់ពេលវេលា។ ត្រូវត្រួតពិនិត្យ និងធ្វើការកែប្រែឲ្យប្រសើរនៅពេលណាដែលចាំបាច់។

*តើអ្នកឆ្ងល់ទេថាហេតុអ្វីបានជាមានសារៈសំខាន់ក្នុងការផ្ដល់ទំនិញមានគុណភាពខ្ពស់ និងមានសេវាកម្មល្អ? ចូរលើកតិតមូលហេតុ២សម្រាប់សំណួរនេះ។*



លើកតម្កើងផលិតផលរបស់អ្នក។ ស្វែងរកមធ្យោបាយច្នៃប្រឌិតដើម្បីផ្សព្វផ្សាយ។ អ្នកចង់មានភាពលេចធ្លោ និងត្រូវគេកត់សម្គាល់។

*តើអ្នកចងចាំយុទ្ធនាការផ្សព្វផ្សាយដ៏ល្អពូកែមួយទេ? តើពាក្យស្លោកណាមួយដែលអ្នកចងចាំបានច្បាស់ល្អ?*



សហគ្រិនពិតប្រាកដតែងតែរក្សាការស្វែងរកមធ្យោបាយដើម្បីធ្វើឲ្យជំនួយរបស់ពួកគេរីកចម្រើន និងធ្វើឲ្យផលិតផលកាន់តែមានគុណភាព។

*តើមធ្យោបាយធ្វើការស្រាវជ្រាវមួយណាដែលនឹងផុចផលល្អក្នុងការស្វែងរកនូវរបៀបដែលអ្នកទិញឲ្យតម្លៃទៅលើផលិតផល ឬសេវាកម្ម?*

## ជំហានទីផ្សារសាមញ្ញៗ

1. ចាប់ផ្ដើមជាមួយការស្រាវជ្រាវទីផ្សារ
2. រៀនពីរបៀបធ្វើផលិតផលឲ្យមានគុណភាព ឬមានសេវាកម្មល្អ
3. គណនាថ្លៃដើម និងប្រាក់ចំណេញ
4. ត្រួតពិនិត្យគុណភាពផលិតផល
5. ផ្សព្វផ្សាយពីផលិតផលរបស់អ្នក



គិត"ក្រៅប្រអប់"!

*តើអ្នកគិតថានេះមានន័យយ៉ាងណា?*

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid

UTSCHE ZUSAMMENARBEIT

giz